ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រអប់រំសុខភាព និង ទំនាក់ទំនងហានិភ័យជំងឺគ្រុនឈាម


មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់
ប៉ារ៉ាស៊ីតសាស្ត្រ និង បាណកសាស្ត្រ
២០២០

## អារម្ភកថា

ជំងឺគ្រុនឈាមនៅតែជាបញ្ហាសុខភាពសាធារណៈសំរាប់ប្រទេសកម្ពុជា ។ កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្របាន សហការជាមួយអង្គការសុខភាពពិភពលោកប្រចាំប្រទេស និងប្រចាំតំបន់បង្កើតយុទ្ធសាស្ត្រ អប់រំសុខភាព និងទំនាក់ទំនងហានិភ័យជំងឺគ្រុនឈាម ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការចូលរួមទប់ស្កាត់ និងឆ្លើយតប មុនការរាតត្បាត និងក្នុងអំឡុងពេលរាតត្បាតជំងឺគ្រុនឈាម។

យុទ្ធសាស្ត្រនេះបង្កើតឡើងក្នុងគោលបំណងបង្កើន និងពង្រឹងសមត្ថភាពថ្នាក់ក្រោមជាតិក្នុងការចលនាសហគមន៍គោលដៅចូលរួមក្នុងការកាត់បន្ថយប្រភពបង្កកំណើតមូសសំអាតលំនៅដ្ឋាន និងអនុវត្តវិធានការការពារមិនឲ្យកើតជំងឺគ្រុនឈាម ជាពិសេសនៅរដូវដែលមានការចម្លងជំងឺខ្ពស់ និងក្នុងពេលមានការរាតត្បាត។

ខ្ញុំឆ្លៀតឱកាសនេះដើម្បីថ្លែងអំណរគុណដល់អ្នកជំនាញជាតិ និងដៃគូរអភិវឌ្ឍន៍ទាំងអស់ដែលបានចូលរួមក្នុងការអភិវឌ្ឍនូវយុទ្ធសាស្ត្រនេះ។

ខ្ញុំជឿជាក់ថា ឯកសារនេះនឹងត្រូវបានផ្សព្វផ្សាយ ក៏ដូចបណ្តុះបណ្តាលបន្តឲ្យមានលក្ខណៈទូលំទូលាយដល់ថ្នាក់ក្រោមជាតិ ដើម្បីជានាឲ្យខ្លឹមសារ និងការណែនាំនៅក្នុងយុទ្ធសាស្ត្រនេះត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ សំរាប់ចូលរួមចំណែកក្នុងការកាត់បន្ថយអត្រាឈឺ និងស្លាប់ដោយសារជំងឺគ្រុនឈាមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃ សុក្រ ១៣រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ កុម្ភៈ ឆ្នាំ២០២០

សាស្ត្រាចារ្យ អេង ហួត
រដ្ឋលេខាធិការ

# បុព្វកថា

ជំងឺគ្រុនឈាមនៅតែជាបញ្ហាសុខភាពសាធារណៈចំបងក្នុងពិភពលោក[i] រួមទាំងប្រទេសកម្ពុជាផង ដែរ។

ជំងឺគ្រុនឈាមត្រូវបានដាក់ចូលទៅក្នុងចំណោមជំងឺអាទិភាព ដោយក្រសួងសុខាភិបាល ត្រូវបានរកឃើញដំបូងនៅក្នុងឆ្នាំ១៩៦៣[ii] ចាប់តាំងពីពេលនោះមកពិសេសតាមរយៈប្រព័ន្ធរបាយការណ៍ជំងឺគ្រុនឈាមរបស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាមបានកត់សំគាល់ឃើញថារៀងរាល់ ៥ ទៅ ៦ ឆ្នាំ ដែលអាចប៉ះពាល់តាមតំបន់មួយចំនួន ឬ ទូទាំងប្រទេស។

ឯកសារនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីពង្រឹងប្រសិទ្ធភាពការងារអប់រំសុខភាព ដែលមានទំនាក់ទំនងជាមួយនឹងហានិភ័យដោយជំងឺគ្រុនឈាម។ ឯកសារនេះតម្រង់ទិសសកម្មភាពការអប់រំសុខភាពនៃជំងឺគ្រុនឈាមទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

យុទ្ធសាស្ត្រនេះធ្វើឡើងដោយស្របជាមួយផែនការសកម្មភាពតំបន់ប៉ាស៊ីហ្វិកខាងលិចសម្រាប់ជំងឺគ្រុនឈាម(ឆ្នាំ២០១៦) និងផែនការសកម្មភាពជាតិសម្រាប់ជំងឺគ្រុនឈាម និងការប្រយុទ្ធនឹងជំងឺឆ្លងឆ្នាំ២០១៨ - ២០២០ យុទ្ធសាស្ត្រនេះសម្រាប់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម និងភាគីពាក់ព័ន្ធនានាដោយកំណត់ផ្លូវដើម្បីសម្រេចគោលដៅកាត់បន្ថយអត្រាជំងឺគ្រុនឈាម និងអត្រាមរណភាពនៅកម្ពុជា។

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់**

**ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ**

**វេជ្ជ. ហ៊ុយ រ៉េកុល**

# សេចក្តីថ្លែងអំណរគុណ

យុទ្ធសាស្ត្រនេះត្រូវបានបង្កើតឡើងដោយមានការគាំទ្រ និងការប្តេជ្ញាចិត្តខ្ពស់របស់លោកវេជ្ជបណ្ឌិត Rabindra Abeyasinghe អ្នកសម្របសម្រួល MVP នៅការិយាល័យប្រចាំតំបន់ប៉ាស៊ីហ្វិកខាងលិចរបស់អង្គការសុខភាពពិភពលោក និងលោកស្រីវេជ្ជបណ្ឌិត Luciano Tusseo នៅការិយាល័យប្រចាំប្រទេសកម្ពុជារបស់អង្គការសុខភាពពិភពលោក។ សូមថ្លែងអំណរគុណដល់ លោកបណ្ឌិត **លាង ឫទ្ធា** ប្រធានកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាមសម្រាប់ការណែនាំរបស់លោកក្នុងដំណើរការកែសម្រួលឯកសារ។ សូមថ្លែងអំណរគុណជាពិសេសចំពោះលោកស្រីវេជ្ជបណ្ឌិត Ljubica Latinovic អ្នកពិគ្រោះយោបល់ផ្នែកទំនាក់ទំនងហានិភ័យនៃការិយាល័យប្រចាំតំបន់ប៉ាស៊ីហ្វិកខាងលិចរបស់អង្គការសុខភាពពិភពលោកសម្រាប់ការចងក្រងនូវយុទ្ធសាស្ត្រនេះ។

# ពាក្យបំព្រួញ និងពាក្យកាត់

| | |
|---|---|
| BCC | ទំនាក់ទំនងផ្លាស់ប្តូរអាកប្បកិរិយា |
| CBO | អង្គការផ្តោតលើសហគមន៍ |
| CDC | នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| CNM | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ |
| DENV | មេរោគគ្រុនឈាម |
| DF | គ្រុនឈាម |
| DHF | ជំងឺគ្រុនឈាម |
| HE | ការអប់រំសុខភាព |
| IEC | ព័ត៌មាន ការអប់រំ និងទំនាក់ទំនង |
| IHR | បទបញ្ញាសុខភាពអន្តរជាតិ |
| MoH | ក្រសួងសុខាភិបាល |
| NAP | ផែនការសកម្មភាពជាតិ |
| NDCP | កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម |
| RC | ទំនាក់ទំនងហានិភ័យ |
| WHO | អង្គការសុខភាពពិភពលោក |
| WPRO | ការិយាល័យតំបន់ប៉ាស៊ីហ្វិចខាងលិច |

# តារាងមាតិកា

អារម្ភកថា ............ Error! Bookmark not defined.

បុព្វកថា ............ 2

សេចក្តីថ្លែងអំណរគុណ ............ 3

ពាក្យបំព្រួញ និងពាក្យកាត់ ............ 4

បរិបទ ............ 6

សេចក្តីផ្តើម ............ 6

គោលដៅ និងគោលបំណង ............ 13

ឯកសារគាំទ្រ ............ 13

ផ្នែកទី១៖ ការអប់រំសុខភាពស្តីពីជំងឺគ្រុនឈាម ............ 14

ផ្នែកទី២៖ ទំនាក់ទំនងហានិភ័យ ............ 21

បញ្ជីធនធាន ............ 32

ឧបសម្ព័ន្ធទី១៖ សារស្តីពីជំងឺគ្រុនឈាម ............ 33

សារស្តីពីចន្លោះរយៈពេលផ្ទុះឡើងនៃជំងឺ ............ 33

សារស្តីពីការផ្ទុះឡើងនៃជំងឺគ្រុនឈាម ............ 39

សារសម្រាប់បុគ្គលិកសុខាភិបាល ............ 45

សារស្តីពីជំងឺគ្រុនឈាមសម្រាប់អ្នកថែទាំកុមារ និងកុមារតូចៗ ............ 49

ឧបសម្ព័ន្ធទី២៖ ផែនការការអប់រំសុខភាព និងទំនាក់ទំនងហានិភ័យសម្រាប់ជំងឺគ្រុនឈាម ឆ្នាំ ២០១៩ - ២០២០ ............ 51

ឧបសម្ព័ន្ធទី៣៖ បញ្ជីត្រួតពិនិត្យទំនាក់ទំនងជំងឺគ្រុនឈាម ............ 61

អំឡុងពេលផ្ទុះឡើងនៃជំងឺ៖ ............ 62

## បរិបទ

### សេចក្តីផ្តើម

ការអប់រំសុខភាពគឺជាសកម្មភាពប្រចាំដែលផ្តល់ឲ្យបុគ្គលនីមួយៗ និងសហគមន៍នូវចំណេះដឹង និងជំនាញក្នុងការធ្វើការសម្រេចចិត្តអំពីសុខភាពផ្ទាល់ខ្លួន និងសុខភាពរបស់មនុស្សជាទីស្រលាញ់របស់ពួកគេ។ ការអប់រំសុខភាពដែលបានរៀបចំបានល្អ និងបានកំណត់គោលដៅគាំទ្រនូវការផ្លាស់ប្តូរអាកប្បកិរិយាជានិរន្តរ៍ដែលនឹងកាត់បន្ថយចំនួនករណី និងហ្រ្វកង់នូវការកើតឡើងជំងឺ។

ទំនាក់ទំនងហានិភ័យ គឺជាផ្នែកមួយនៃសមត្ថភាពសង្គ្រោះបន្ទាន់ផ្នែកសុខភាពស្នូលដែលត្រូវបានតម្រូវនៅក្រោមបទបញ្ញាសុខភាពអន្តរជាតិ (IHR ឆ្នាំ២០០៥)។ នេះគឺជាការផ្លាស់ប្តូរព័ត៌មាន និងការប្រឹក្សាគ្នាទៅវិញទៅមករវាងអាជ្ញាធរ និងប្រជាជនដែលកំពុងមានគ្រោះថ្នាក់ដោយអនុញ្ញាតឲ្យប្រជាជនចាត់វិធានការយ៉ាងឆាប់រហ័សដើម្បីការពារខ្លួន ក្រុមគ្រួសារ និងសហគមន៍របស់ពួកគេអំឡុងពេលមានគ្រោះថ្នាក់សុខភាព។ ការរៀបចំផែនការកម្រិតខ្ពស់អាចជួយសម្រួលដល់ការចាត់វិធានការរហ័ស និងកាន់តែមានប្រសិទ្ធភាពជាងមុនក្នុងពេលមានគ្រោះថ្នាក់សុខភាព។

ឯកសារនេះដាក់ចេញនូវយុទ្ធសាស្ត្រមួយស្តីពីការអប់រំសុខភាព និងទំនាក់ទំនងហានិភ័យជំងឺគ្រុនឈាមប្រកបដោយប្រសិទ្ធភាព អំឡុងពេលរដូវកាលមានករណីជំងឺកម្រិតទាបក៏ដូចជាអំឡុងពេលនៃការផ្ទុះឡើងនៃជំងឺ។ យុទ្ធសាស្ត្រនេះមានគោលបំណងគាំទ្រដល់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម និងភាគីពាក់ព័ន្ធដទៃទៀតដែលជាផ្នែកមួយនៃវិធានការរួមសម្រាប់ការទប់ស្កាត់ និងកាត់បន្ថយការផ្ទុះឡើងនៃជំងឺគ្រុនឈាម។ វាក៏តម្រឹមសកម្មភាពទំនាក់ទំនង និងការអប់រំស្របទាំងផែនការសកម្មភាពតំបន់ ប៉ាស៊ីហ្វិកខាងលិចសម្រាប់ជំងឺគ្រុនឈាម (ឆ្នាំ២០១៦) និងផែនការសកម្មភាពជាតិសម្រាប់ជំងឺគ្រុនឈាម និងការទប់ស្កាត់ និងប្រយុទ្ធនឹងជំងឺឆ្លងរាលដាលដោយការខាំរបស់សត្វល្អិតផ្សេងទៀតឆ្នាំ២០១៨-២០២០ ដែលជាសមត្ថភាពមួយនៃសមត្ថភាពអន្តរវិស័យក្នុងទំនាក់ទំនងហានិភ័យ និងទំនាក់ទំនងសុខភាព។

### ជំងឺគ្រុនឈាម

ជំងឺគ្រុនឈាមឆ្លងតាមរយៈមូសញីមានមេរោគខាំ ជាពិសេស គឺមូស Aedes Aegypti ដែលរីករាលដាលដល់ប្រទេសកម្ពុជា។ ជំងឺគ្រុនឈាមត្រូវបានសម្គាល់ដោយគ្រុនក្តៅខ្លាំងរួមទាំងការឈឺក្បាល ការ

ឈឺចាប់នៅពីក្រោយភ្នែក ឈឺសាច់ដុំ និងសន្លាក់ និងឡើងកន្ទួលក្រហមដែលជាធម្មតាមានរយៈពេល២-៧ថ្ងៃ។ មនុស្សភាគច្រើនជាសះស្បើយឡើងវិញដោយមិនមានផលវិបាករយៈពេលវែងណាមួយឡើយ។ ជួនកាល រោគសញ្ញាជំងឺគ្រុនឈាមអាចស្រាល និងងាយច្រឡំជាមួយនឹងជំងឺដទៃទៀតដែលចាប់ផ្ដើមចេញពីជំងឺគ្រុន។ មនុស្សម្នាក់ក្នុងចំណោមមនុស្សបួននាក់ដែលឆ្លងជំងឺគ្រុនឈាមនឹងមិនមានរោគសញ្ញាអ្វីឡើយ ប៉ុន្តែពួកគេអាចចម្លងមេរោគនេះទៅអ្នកដទៃទៀតបាន។

ជំងឺគ្រុនឈាមម្ដងម្កាលអាចវិវឌ្ឍទៅជាផលវិបាកដ៏សាហាវមួយដែលហៅថាជំងឺគ្រុនឈាមធ្ងន់ធ្ងរ - ដែលជាអាទិភាពចំបងបំផុតសម្រាប់ការថែទាំសុខភាពឲ្យបានទាន់ពេលវេលា និងគ្រប់គ្រាន់។ សញ្ញាព្រមាននៃជំងឺគ្រុនឈាមធ្ងន់ធ្ងរលេចឡើងរវាងថ្ងៃទី៣ និងថ្ងៃទី៧ នៃជំងឺ ហើយរួមមានការចុះថយគ្រុនក្ដៅភ្លាមៗរួមទាំងការក្អួតបន្តបន្ទាប់ ឈឺពោះធ្ងន់ធ្ងរ ហូរឈាមចេញតាមច្រមុះ និងអញ្ចាញធ្មេញ មានឈាមពេលក្អួត ធាប់ខឹង និងអស់កម្លាំង។ ជំងឺគ្រុនឈាមធ្ងន់ធ្ងរ ជាគ្រោះអាសន្នមួយខាងវេជ្ជសាស្ត្រ។ ការថែទាំវេជ្ជសាស្ត្រដោយវេជ្ជបណ្ឌិត និងគិលានុបដ្ឋាក គិលានុបដ្ឋាយិកាដែលមានបទពិសោធន៍ពីផលប៉ះពាល់និងការវិវឌ្ឍនៃជំងឺនេះអាចជួយសង្គ្រោះជីវិតមនុស្សបាន។ ការថែរក្សាបរិមាណសារធាតុរាវនៃរាងកាយរបស់អ្នកជំងឺគឺមានសារសំខាន់ចំពោះការទប់ស្កាត់ជំងឺគ្រុនឈាមធ្ងន់ធ្ងរ (អង្គការសុខភាពពិភពលោក)។

មេរោគគ្រុនឈាមមាន ៤ប្រភេទ។ ការឆ្លងមេរោគ និងការជាសះស្បើយពីប្រភេទមេរោគមួយមិនផ្ដល់នូវភាពស៊ាំសម្រាប់ប្រភេទដទៃទៀតនោះទេ៖ ការឆ្លងជាបន្តបន្ទាប់ដោយមីក្រូសរីរាង្គផ្សេងទៀតអាចបណ្ដាលឲ្យមានជំងឺគ្រុនឈាមធ្ងន់ធ្ងរ។ នេះមានន័យថា មនុស្សគ្រប់រូបដែលរស់នៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយជំងឺគ្រុនឈាមនឹងមានហានិភ័យជាប្រចាំ។ ទោះជាយ៉ាងណាក៏ដោយ មានការយល់ឃើញថាកុមារ ជាពិសេសទារក អាចវិវឌ្ឍទៅជាជំងឺគ្រុនឈាមធ្ងន់ធ្ងរកាន់តែញឹកញាប់។

ទោះបីជាមិនមានការព្យាបាលជាក់លាក់រហូតដល់សព្វថ្ងៃនេះក៏ដោយ ការធ្វើរោគវិនិច្ឆ័យដំណាក់កាលដំបូង និងការថែទាំវេជ្ជសាស្ត្រត្រឹមត្រូវអាចជួយសង្គ្រោះជីវិតបាន។ ខណៈពេលដែលការឆ្លងជំងឺគ្រុនឈាមមួយចំនួនមិនអាចចៀសផុតបាននៅក្នុងប្រទេសដែលឆ្លងរាលដាល នោះវត្តមាននៃមេរោគជំងឺគ្រុនឈាមអាចត្រូវបានកម្រិតតាមរយៈការត្រួតពិនិត្យវ៉ិចទ័រប្រកបដោយប្រសិទ្ធភាព និងចីរភាពដែលរួមមាន៖

- ទប់ស្កាត់កុំឲ្យមូសពងតាមរយៈការបំបាត់ជម្រកមូស
- បោលកាកសំណល់រឹងឲ្យបានត្រឹមត្រូវ
- គ្រប ចាក់ចោល និងសម្អាតពាងទឹកនៅក្នុងគ្រួសាររៀងរាល់សប្ដាហ៍
- ប្រើថ្នាំសម្លាប់សត្វល្អិតសមស្របនៅក្នុងពាងទឹកនៅខាងក្រៅលំនៅឋាន

- ប្រើវិធានការការពារលំនៅឋានផ្ទាល់ខ្លួន ដូចជា កញ្ចក់បង្អួច សម្លៀកបំពាក់អាវដៃវែង ថ្នាំលាបបណ្តេញសត្វល្អិត សម្ភារជ្រលក់ថ្នាំសម្លាប់សត្វល្អិត ធូប និងឧបករណ៍បញ្ចេញចំហាយសម្លាប់សត្វល្អិតនៅពេលព្រឹកព្រលឹម និងពេលរសៀល។ ការប្រើប្រាស់នេះត្រូវបានផ្តល់អនុសាសន៍អនុវត្តតាមវិធានការទាំងនេះនៅពេលថ្ងៃទាំងនៅលំនៅឋាន និងកន្លែងធ្វើការ ដោយសារមូសខាំនៅពេលថ្ងៃផងដែរ
- ធ្វើឲ្យប្រសើរឡើងនូវការចូលរួមរបស់សហគមន៍ និងការកៀរគរសហគមន៍សម្រាប់ការគ្រប់គ្រងប្រកបដោយចីរភាពនូវសត្វល្អិតចម្លងមេរោគ
- ប្រើមុងសម្រាប់អ្នកជំងឺគ្រុនឈាមនៅលំនៅឋាន និងនៅក្នុងមូលដ្ឋានសុខាភិបាលដើម្បីការពារអ្នកដទៃ ជាពិសេសអ្នកថែទាំអ្នកជំងឺ
- ប្រើថ្នាំសម្លាប់សត្វល្អិតជាការបាញ់ថ្នាំក្នុងលំហនៅពេលមានការផ្ទុះឡើងនៃជំងឺជាវិធានការគ្រប់គ្រងសត្វចម្លងមេរោគបន្ទាន់ក្នុងចន្លោះ និងពេលវេលាមានកំណត់។
- ការត្រួតពិនិត្យ និងឃ្លាំមើលយ៉ាងសកម្មនូវសត្វល្អិតចម្លងមេរោគគួរតែត្រូវបានអនុវត្តដើម្បីកំណត់ប្រសិទ្ធភាពនៃអន្តរាគមន៍គ្រប់គ្រង។

ការផ្ទុះឡើងនៃជំងឺគ្រុនឈាម និងជំងឺរាតត្បាតច្រើនតែមានលំនាំតាមរដូវកាលដោយករណីមួយចំនួនច្រើនប៉ុន្តែខ្ពស់បំផុតក្នុងអំឡុងពេលរដូវវស្សា។ ទោះជាយ៉ាងណាក៏ដោយ ការប្រែប្រួលអាកាសធាតុ នគរូបនីយកម្មឆាប់រហ័ស កង្វះហេដ្ឋារចនាសម្ព័ន្ធចាំបាច់សម្រាប់ការផ្គត់ផ្គង់ទឹកក្នុងចំណោមបញ្ហាផ្សេងទៀត អាចក្លាយជាហេតុផលនៃការផ្ទុះឡើងនៃជំងឺកាន់តែញឹកញាប់ ប្រសិនបើវិធានការទប់ស្កាត់ និងគ្រប់គ្រងមិនត្រូវបានពង្រឹងនោះ។

## ការអប់រំសុខភាព

ការអប់រំសុខភាពត្រូវបានកំណត់ថា ជាការរួមបញ្ចូលគ្នានៃបទពិសោធន៍រៀនសូត្រ ដែលបានបង្កើតឡើងដើម្បីជួយបុគ្គល និងសហគមន៍ក្នុងការលើកកម្ពស់ ថែរក្សា និងស្តារសុខភាពរបស់ពួកគេឡើងវិញដោយបង្កើនចំណេះដឹង ឬជះឥទ្ធិពលដល់ឥរិយាបថរបស់ពួកគេចំពោះ**ការផ្លាស់ប្តូរអាកប្បកិរិយាដោយស្ម័គ្រចិត្ត** ដែលនឹងការពារបុគ្គល និងសហគមន៍ពីជំងឺជាក់លាក់ និងទប់ស្កាត់ការផ្ទុះឡើងនៃជំងឺនានា។ ការអប់រំសុខភាព គឺជាសមាសធាតុសំខាន់មួយនៃការទប់ស្កាត់ និងប្រយុទ្ធនឹងជំងឺគ្រុនឈាមដោយធានាថា ទស្សនិកជនគោលដៅទទួលបានភាពច្បាស់លាស់ និងភាពងាយស្រួលដើម្បីអនុវត្តតាមសារដែលនឹង

ជួយសម្រួលដល់ការកែប្រែឥរិយាបថសំខាន់ៗ ដែលចាំបាច់ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺ កាត់បន្ថយភាពស្មុគស្មាញ និងចៀសវាងមរណភាព។ ការអប់រំសុខភាពនេះ ភាគច្រើនធ្វើនៅកម្រិតសហគមន៍តាមរយៈការអប់រំសុខភាពនៅតាមសាលារៀន កន្លែងធ្វើការ និងមណ្ឌលសុខភាព។

ទោះយ៉ាងណាក៏ដោយ យុទ្ធនាការអប់រំអំពីជំងឺគ្រុនឈាមមិនមែនចេះតែទទួលបានជោគជ័យហេតុនោះទេ ពីព្រោះគេរៀបចំឡើងមិនមានផែនការជាក់លាក់ មិនសម្រាប់គោលដៅជាក់លាក់ និងខ្វះការពន្យល់គ្រប់គ្រាន់អំពីអត្ថប្រយោជន៍នៃការកែប្រែការប្រព្រឹត្ត។ ដើម្បីប្រែក្លាយពីការគ្រាន់តែចែករំលែកព័ត៌មានទៅជាការផ្លាស់ប្តូរអាកប្បកិរិយានោះ អ្នកជំនាញខាងអប់រំសុខភាពកំពុងនាំមុខនាពេលបច្ចុប្បន្នកំពុងប្រើវិធីសាស្ត្រផ្សព្វផ្សាយសង្គមមួយដែលរួមបញ្ចូល "4Ps"៖ ផលិតផល (អាកប្បកិរិយាដែលចង់បាន) តម្លៃ (ថ្លៃដើមខាងសេដ្ឋកិច្ច ឬអារម្មណ៍នៃការផ្លាស់ប្តូរអាកប្បកិរិយា) ទីកន្លែង (កន្លែងដែលអាចរកទស្សនិកជនគោលដៅបាន) និងការផ្សព្វផ្សាយ (សារ និងបណ្តាញ)។

ការអប់រំសុខភាពអំពីជំងឺគ្រុនឈាមគួរតែធ្វើជាប្រចាំ និងត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំដោយឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនគោលដៅ សម្រាប់យុទ្ធសាស្ត្រអប់រំសុខភាពជាក់លាក់ដែលនឹងជំរុញនូវគោលបំណងរបស់ពួកគេចំពោះវិធានការប្រកបដោយចីរភាពនានាដើម្បីទប់ស្កាត់ជំងឺគ្រុនឈាម។

## ទំនាក់ទំនងហានិភ័យ

ទំនាក់ទំនងហានិភ័យគឺជាការផ្លាស់ប្តូរព័ត៌មាន ដំបូន្មាន និងយោបល់ជាក់ស្តែងរវាងអ្នកជំនាញ អ្នកដឹកនាំសហគមន៍ មន្ត្រី និងប្រជាជនដែលកំពុងមានហានិភ័យ និងជាផ្នែកសំខាន់មួយនៃការឆ្លើយតបនឹងគ្រោះអាសន្នណាមួយ។ នៅក្នុងពេលរោគរាតត្បាត និងរោគឆ្លង នៅក្នុងវិបត្តិមនុស្សធម៌ និងគ្រោះមហន្តរាយធម្មជាតិ ទំនាក់ទំនងហានិភ័យប្រកបដោយប្រសិទ្ធភាព**អនុញ្ញាតឲ្យមនុស្សដែលកំពុងមានហានិភ័យអាចយល់ និងប្រើប្រាស់អាកប្បកិរិយាការពារ។** វាអនុញ្ញាតឲ្យអាជ្ញាធរ និងអ្នកជំនាញស្តាប់ និងដោះស្រាយក្តីកង្វល់ និងតម្រូវការនានារបស់ប្រជាជន ដូច្នេះដំបូន្មានដែលពួកគេផ្តល់មានការពាក់ព័ន្ធ អាចជឿទុកចិត្តបាន និងអាចទទួលយកបាន (គោលការណ៍ណែនាំ អង្គការសុខភាពពិភពលោក ឆ្នាំ២០១៧)

ដោយសារជំងឺគ្រុនឈាមជាជំងឺមួយក្នុងចំណោមជំងឺបង្កឡើងពីសត្វមូស ដែលរីករាលដាលលឿនបំផុតមានសក្តានុពលក្នុងការបង្កឲ្យមានការផ្ទុះឡើង និងការរីករាលដាលនៃជំងឺ បានជាទំនាក់ទំនងហានិភ័យគឺជាធាតុផ្សំដ៏សំខាន់សម្រាប់ការរៀបចំផែនការ និងការឆ្លើយតបនឹងការផ្ទុះឡើងនៃជំងឺគ្រុនឈាម។

ទំនាក់ទំនងហានិភ័យប្រកបដោយប្រសិទ្ធភាពតម្រូវឲ្យមានតម្លាភាព ការប្រកាសបានមុន ការគ្រប់គ្រងភាពមិនច្បាស់លាស់ ហើយសំខាន់បំផុតគឺការរក្សាបាននូវទំនុកចិត្ត។ ការជឿទុកចិត្តអាចត្រូវបានរក្សាបានដោយផ្តល់ព័ត៌មានទាន់ពេលវេលា ពាក់ព័ន្ធ គួរឲ្យទុកចិត្ត និងដោយបង្ហាញការយកចិត្តទុកដាក់ចំពោះសហគមន៍ដែលរងផលប៉ះពាល់។

ដើម្បីបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងហានិភ័យប្រកបដោយប្រសិទ្ធភាព វាសំខាន់ណាស់ក្នុងការវាយតម្លៃការយល់ឃើញពីហានិភ័យរបស់ប្រជាជនដែលរស់នៅក្នុងតំបន់ ដែលរងផលប៉ះពាល់ដោយសារជំងឺគ្រុនឈាម។ ហានិភ័យដែលអ្នកជំនាញបានដឹង (អ្នកគ្រប់គ្រងជំងឺគ្រុនឈាម មន្ត្រីសុខាភិបាល) មិនមែនដូចអ្វីដែលសហគមន៍បានដឹងនោះទេ។ សាធារណជនទូទៅទំនងជាយល់ឃើញថា ហានិភ័យខ្ពស់នៅពេលជួបគ្រោះថ្នាក់ដោយចៃដន្យ ដែលមិនអាចផ្លាស់ប្តូរបាន មិនសូវយល់ដឹង មិនបានរំពឹងទុក មិនស្គាល់ មិនអាចគ្រប់គ្រងបាន អយុត្តិធម៌ និង/ឬប៉ះពាល់ដល់ជនដែលងាយរងគ្រោះ។ ផ្ទុយទៅវិញ ជាទូទៅ មនុស្សមិនសូវព្រួយបារម្ភអំពីហានិភ័យដែលពួកគេជួបប្រទះជាប្រចាំនោះទេ។ ជំងឺគ្រុនឈាមគឺជាឧទាហរណ៍ដ៏ល្អមួយនៃបញ្ហានេះ។ នៅកន្លែងដែលមានជំងឺគ្រុនឈាមរាលដាល ប្រជាជនក្នុងស្រុកច្រើនតែមិនមានការបារម្ភអំពីជំងឺគ្រុនឈាម ដោយសារវាជាហានិភ័យដែលពួកគេបានជួបប្រទះជាច្រើនឆ្នាំមកហើយ។ នេះធ្វើឲ្យទំនាក់ទំនងហានិភ័យមានប្រសិទ្ធភាពមានការលំបាក។ ជួនកាល វាចាំបាច់ត្រូវលើកកម្ពស់ការយល់ឃើញរបស់ប្រជាជនអំពីហានិភ័យ ឬបង្កឲ្យមានប្រតិកម្មអារម្មណ៍ដើម្បីជំរុញឲ្យពួកគេចាត់វិធានការ និងប្រើអាកប្បកិរិយាការពារ។

ក្នុងអំឡុងពេលឆ្លើយតបទៅនឹងការផ្ទុះឡើងនៃជំងឺ ការសម្របសម្រួលទំនាក់ទំនងហានិភ័យគឺមានសារសំខាន់៖ រវាងស្ថាប័នផ្សេងៗគ្នានៅក្នុងក្រសួងសុខាភិបាលក៏ដូចជា ជាមួយដៃគូខាងក្រៅ និងភាគីពាក់ព័ន្ធ។ ការសម្របសម្រួលមានសារសំខាន់ណាស់ក្នុងការបង្កើតពិធីសារ និងយន្តការសម្របសម្រួលជាមុនដើម្បីចៀសវាងស្ថានភាពមួយដែលសារផ្សេងៗគ្នាត្រូវបានបញ្ចេញដោយស្ថាប័នផ្សេងៗ ដោយបង្កើតឲ្យមានការភាន់ច្រឡំ និងប៉ះពាល់ដល់ការជឿទុកចិត្ត។ ម្យ៉ាងវិញទៀត សារដែលមានការសម្របសម្រួលល្អ ទាន់ពេលវេលា និងបានកំណត់យ៉ាងច្បាស់ជាមួយនឹងការអំពាវនាវឲ្យមានវិធានការសម្រាប់ការកាត់បន្ថយជំងឺគ្រុនឈាម អាចការពារក្រុមគ្រួសារ និងសហគមន៍ និងជួយសង្គ្រោះជីវិត។

## សារសំខាន់នៃការដឹង៖

ការអប់រំសុខភាព និងទំនាក់ទំនងហានិភ័យមិនមែនជាសមាសធាតុដាច់ដោយឡែកនៃយុទ្ធសាស្ត្រទំនាក់ទំនងសម្រាប់ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងជំងឺគ្រុនឈាមទេ ពួកគេបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក។ ទោះជាយ៉ាងណាក៏ដោយ ដោយសារលក្ខណៈនៃស្ថានភាពសុខភាព (ហានិភ័យធ្ងន់ធ្ងរធៀបនឹងហានិភ័យដែលមានស្រាប់) ទំនាក់ទំនងហានិភ័យ និងការអប់រំសុខភាពអាចត្រូវបានប្រើនៅពេលវេលាផ្សេងៗគ្នាទាន់ពេលដោយផ្អែកលើចំណុចដូចខាងក្រោម៖

**តារាងទី១៖ ទំនាក់ទំនងហានិភ័យ និងការអប់រំសុខភាព**

| ទំនាក់ទំនងហានិភ័យ | ការអប់រំសុខភាព |
| --- | --- |
| ក្នុងការឆ្លើយតបនឹងការផ្ទុះឡើងនៃជំងឺ និងគ្រោះអាសន្នផ្នែកសុខភាព – ហានិភ័យធ្ងន់ធ្ងរ | រយៈពេលយូរ ជាប្រចាំ និងដដែលៗ |
| កាលៈទេសៈអាចផ្លាស់ប្តូរ – នៅកណ្តាលភាពមិនច្បាស់លាស់ | បញ្ហាសុខភាពដែលបានដឹង |
| ទប់ស្កាត់ និងកាត់បន្ថយ | លើកកម្ពស់ និងទប់ស្កាត់ |
| ត្រូវការការចាត់វិធានការភ្លាមៗ | ត្រូវការការផ្លាស់ប្តូរដោយស្ម័គ្រចិត្ត |
| ផ្អែកលើការយល់ឃើញ | ផ្អែកលើផលប្រយោជន៍ និងការលើកទឹកចិត្ត |
| អាកប្បកិរិយាការពារ | ផលប្រយោជន៍នៃអាកប្បកិរិយានោះ |

**ការអប់រំសុខភាព និងទំនាក់ទំនងហានិភ័យផ្អែកលើ៖**

គោលបំណងទំនាក់ទំនងសំខាន់មួយ (លទ្ធផលទំនាក់ទំនងសំខាន់មួយ)

ទស្សនិកជនគោលដៅ

សារ

## គោលដៅ និងគោលបំណង

### គោលដៅ៖

ដើម្បីផ្តល់នូវគោលការណ៍ណែនាំស្តីពីទំនាក់ទំនង និងការអប់រំអំពីការផ្ទុះឡើងនៃជំងឺគ្រុនឈាម និងក្នុងរដូវកាលមានជំងឺគ្រុនឈាមកម្រិតទាប ស្របនឹង WPR DAP និងផែនការសកម្មភាពជាតិក្នុងគោលបំណងដើម្បីសម្រេចគោលដៅ កាត់បន្ថយផលប៉ះពាល់សុខភាពដោយសារជំងឺគ្រុនឈាមនៅកម្ពុជា។

### គោលបំណង៖

- បញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវ និងបង្កើតយន្តការសម្របសម្រួលសម្រាប់ការអប់រំសុខភាព និងទំនាក់ទំនងហានិភ័យជំងឺគ្រុនឈាម
- កំណត់ទស្សនិកជនគោលដៅ សារសំខាន់ និងបណ្តាញទំនាក់ទំនងសមស្រប
- គូសបញ្ជាក់ផែនទីបង្ហាញផ្លូវសម្រាប់លំហូរព័ត៌មានសម្រាប់គោលបំណងនៃទំនាក់ទំនងហានិភ័យ និងការអប់រំសុខភាព
- បញ្ជាក់ពីសកម្មភាពអប់រំសុខភាពដែលត្រូវធ្វើឡើងក្នុងអំឡុងពេលការឆ្លងជំងឺកម្រិតទាប
- កំណត់សកម្មភាពទំនាក់ទំនងហានិភ័យក្នុងអំឡុងពេលផ្ទុះឡើងនៃជំងឺ

## ឯកសារគាំទ្រ

- ផែនការសកម្មភាពតំបន់ប៉ាស៊ីហ្វិកខាងលិចសម្រាប់ការទប់ស្កាត់ និងការគ្រប់គ្រងជំងឺគ្រុនឈាម (ឆ្នាំ២០១៦)
- ផែនការសកម្មភាពជាតិសម្រាប់ជំងឺគ្រុនឈាម និងការទប់ស្កាត់ និងការគ្រប់គ្រងជំងឺឆ្លងដោយសារសត្វល្អិតខាំផ្សេងៗទៀត ( ឆ្នាំ២០១៨- ២០២០ )
- យុទ្ធសាស្ត្រអាស៊ីប៉ាស៊ីហ្វិកសម្រាប់ជំងឺដែលកំពុងលេចចេញ និងគ្រោះអាសន្នផ្នែកសុខភាពសាធារណៈ (APSED III – ឆ្នាំ២០១៧)
- យុទ្ធសាស្ត្រទំនាក់ទំនងហានិភ័យ៖ គោលការណ៍ និងពិធីសាស្ត្រ (ក្រសួងសុខាភិបាល – ឆ្នាំ២០១៤)

## ផ្នែកទី១៖ ការអប់រំសុខភាពស្តីពីជំងឺគ្រុនឈាម

កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម គឺជាអ្នកនាំមុខខាងបច្ចេកទេសសម្រាប់រាល់សកម្មភាពទាក់ទងនឹងជំងឺគ្រុនឈាម រួមមានការអប់រំសុខភាព និងទំនាក់ទំនងហានិភ័យ។ ការអប់រំសុខភាពត្រូវបានផ្តល់ជូនតាមរយៈសកម្មភាពផ្សព្វផ្សាយរបស់មណ្ឌលសុខភាព និងការអន្តរាគមន៍សហគមន៍តាមសាលារៀន និងភូមិ។ សារ និងសម្ភារព័ត៌មាន ការអប់រំ និងទំនាក់ទំនងត្រូវបានផលិតដោយផ្នែកបច្ចេកទេសការអប់រំសុខភាពរបស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម។ សារភាគច្រើនទាក់ទងនឹងការលុបបំបាត់ជម្រកមូស វដ្តជីវិតមូស និងការស្គាល់នូវរោគសញ្ញាជំងឺគ្រុនឈាម។

ការអប់រំសុខភាពស្តីពីជំងឺគ្រុនឈាមរួមបញ្ចូលទាំងយុទ្ធសាស្ត្រទំនាក់ទំនង ក្នុងរដូវកាលមានជំងឺគ្រុនឈាមកម្រិតទាប នៅពេលដែលករណីមួយចំនួនត្រូវបានបង្ហាញដើម្បីផ្តល់អំណាចដល់សហគមន៍ និងកសាងអាកប្បកិរិយាសុខភាពប្រកបដោយនិរន្តរភាព។ ការអប់រំត្រូវបានពង្រឹងក្នុងអំឡុងពេលផ្ទុះឡើងនៃជំងឺដើម្បីពង្រឹងការប្រព្រឹត្តិផ្នែកសុខភាពនានា ដែលចាំបាច់ដើម្បីកាត់បន្ថយស្ថានភាព និងកាត់បន្ថយផលប៉ះពាល់នៃជំងឺគ្រុនឈាម។

### ការដឹកនាំការអប់រំសុខភាព

កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម/មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ

**<u>តួនាទី៖</u>**

- វាយតម្លៃចំណេះដឹង អាកប្បកិរិយា និងការអនុវត្តរបស់ប្រជាជនតាមរយៈការសិក្សា KAP ទៀងទាត់ ការពិភាក្សាក្រុមផ្តោតលើការងារ ឬវិធីសាស្ត្រផ្សេងៗ
- កំណត់ទស្សនិកជនគោលដៅជាក់លាក់ និងតម្រូវការរបស់ពួកគេសម្រាប់ព័ត៌មានអំពីជំងឺគ្រុនឈាម
- កំណត់គោលដៅទំនាក់ទំនង និងគោលបំណងទំនាក់ទំនងសំខាន់មួយ
- បង្កើតសារនានា
- ជ្រើសរើសបណ្តាញគ្រប់គ្រាន់សម្រាប់ផ្សព្វផ្សាយសារ
- សម្របសម្រួលជាមួយនឹងនាយកដ្ឋាននានារបស់ក្រសួងសុខាភិបាលសម្រាប់ការពន្យល់អំពីសម្ភារជាក់លាក់នានា (ដូចជា អ្នកផ្តល់ការថែទាំសុខភាព)
- ចែកចាយសម្ភារព័ត៌មាន ការអប់រំ និងទំនាក់ទំនងដល់ថ្នាក់ខេត្ត

## ភាគីពាក់ព័ន្ធផ្ទៃក្នុង

គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម

នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង

អនុគណៈកម្មការគ្លីនិក

ឃ្លាំងឱសថកណ្តាល

មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព

នាយកដ្ឋានសេវាមន្ទីរពេទ្យ

<u>តួនាទី៖</u>

- ផ្តល់ជំប្ញូន្ទានសម្រាប់សារ និងសម្ភារនានាសម្រាប់ទស្សនិកជនគោលដៅជាក់លាក់
- ចែករំលែកព័ត៌មាន និងសម្ភារព័ត៌មាន ការអប់រំ និងទំនាក់ទំនងអំពីវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមនានារបស់ពួកគេ

## សមភាគីថ្នាក់ក្រោមជាតិ៖

មន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ មណ្ឌលសុខភាព មូលដ្ឋានសុខាភិបាល

អ្នកគ្រប់គ្រងជំងឺគ្រុនឈាមខេត្តទាំងអស់

<u>តួនាទី៖</u>

- ចែកចាយសម្ភារព័ត៌មាន ការអប់រំ និងទំនាក់ទំនងដល់មណ្ឌលសុខភាព សាលារៀន វត្តអារាម កន្លែងការងារ ជាដើម
- ធ្វើសកម្មភាពអប់រំសុខភាព និងទំនាក់ទំនងហានិភ័យនៅថ្នាក់ក្រោមខេត្ត
- លើកកម្ពស់ការយល់ដឹងរបស់អ្នកមានឥទ្ធិពលក្នុងសហគមន៍អំពីជំងឺគ្រុនឈាម

# នីតិវិធីប្រតិបត្តិការស្តង់ដារ



## ទស្សនិកជនគោលដៅ និងគោលបំណងទំនាក់ទំនងសំខាន់មួយ

| ទស្សនិកជនគោលដៅ | គោលបំណងទំនាក់ទំនង | គោលបំណងទំនាក់ទំនងសំខាន់មួយ – លទ្ធផលនៃទំនាក់ទំនងរបស់យើង |
|---|---|---|
| សាធារណជនទូទៅ | លើកកម្ពស់ការយល់ដឹងអំពីហានិភ័យនាពេលបច្ចុប្បន្នរបស់ជំងឺគ្រុនឈាម និងការផ្ទុះឡើងនៃជំងឺដែលអាចកើតមាន ហើយផ្តល់ព័ត៌មានអំពីហានិភ័យ និងណែនាំដើម្បីសម្រេចបាននូវអាកប្បកិរិយាការពារប្រកបដោយនិរន្តរភាព | សហគមន៍អនុវត្តការសម្អាតបរិស្ថាន និងការបំបាត់ជម្រកមូសម្តងក្នុងមួយសប្តាហ៍ |
| **អ្នកថែទាំទារក និងកុមារ** | ផ្តល់ព័ត៌មានសម្រាប់ការស្គាល់ដំណាក់កាលដំបូងនូវរោគសញ្ញាជំងឺគ្រុនឈាម និងអ្វីត្រូវធ្វើប្រសិនបើកុមារមានជំងឺដោយសារជំងឺគ្រុនឈាម | អ្នកថែទាំដឹងពីរោគសញ្ញាជំងឺគ្រុនឈាម និងពេលវេលា និងទីកន្លែងត្រូវស្វែងរកការថែទាំសុខភាព |
| **អាជ្ញាធរក្នុងស្រុក និង អ្នកដឹកនាំ/អ្នកមានឥទ្ធិពលក្នុងសហគមន៍**នៅក្នុងសហគមន៍ដែលកំពុងបង្ហាញនូវករណីជំងឺ | មានចំណេះដឹង និងព័ត៌មានដើម្បីក្លាយជាភ្នាក់ងារការផ្លាស់ប្តូរអាកប្បកិរិយា និងលើកកម្ពស់វិធានការផ្ទាល់ខ្លួន និងបរិស្ថានគ្រប់គ្រាន់ដើម្បីកាត់បន្ថយជំងឺគ្រុនឈាមនៅក្នុងសហគមន៍របស់ពួកគេ | អាជ្ញាធរក្នុងស្រុក អ្នកដឹកនាំសហគមន៍ និងអ្នកមានឥទ្ធិពលក្នុងសហគមន៍តស៊ូមតិដើម្បីវិធានការរបស់សហគមន៍ដើម្បីទប់ស្កាត់ និងគ្រប់គ្រងជំងឺគ្រុនឈាមប្រកបដោយចីរភាព |
| **អ្នកសម្រេចចិត្ត**ពីក្រសួងសុខាភិបាល និងគ្រប់កម្រិតទាំងអស់រដ្ឋាភិបាល | លើកកម្ពស់ការយល់ដឹងពីសារសំខាន់នៃការទប់ស្កាត់ និងគ្រប់គ្រងជំងឺគ្រុនឈាម ហើយតស៊ូមតិដើម្បីវិធានការជានិរន្តរនៅក្នុងក្រសួងសុខាភិបាល និងជាមួយនឹងភាគីពាក់ព័ន្ធរដ្ឋាភិបាលនានា។ | ភាគីពាក់ព័ន្ធទាំងអស់ចូលរួមក្នុងសកម្មភាពសម្របសម្រួលទំនាក់ទំនងជំងឺគ្រុនឈាម |

| | | |
|---|---|---|
| **អ្នកបង្កើតគោលនយោបាយ ម្ចាស់ជំនួយភាគីពាក់ព័ន្ធអន្តរជាតិ និងទីភ្នាក់ងារផ្សេងៗរបស់អង្គការសហប្រជាជាតិ** | តស៊ូមតិដើម្បីការយល់ដឹងកាន់តែប្រសើរអំពីផលប៉ះពាល់របស់ជំងឺគ្រុនឈាមលើសុខភាព សេដ្ឋកិច្ច និងសង្គម និងលើកកម្ពស់ការយល់ដឹងពីកិច្ចសហប្រតិបត្តិការ និងការកៀរគរធនធានដើម្បីកាត់បន្ថយបន្ទុកនៃជំងឺនានា | ធនធានត្រូវបានកៀរគរសម្រាប់ការទប់ស្កាត់ និងប្រយុទ្ធនឹងជំងឺគ្រុនឈាមនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ |
| **ទីកន្លែងនានារបស់សាលារៀន** | ផ្តល់ដល់អាជ្ញាធរសាលារៀន និងសិស្សនូវចំណេះដឹង និងឧបករណ៍នានាដើម្បីក្លាយជាអ្នកផ្សព្វផ្សាយការទប់ស្កាត់ជំងឺគ្រុនឈាមនៅក្នុងសហគមន៍របស់ខ្លួន | សាលារៀនចូលរួមក្នុងកម្មវិធី “សាលារៀនគ្មានកន្លែងបង្កកំណើតមូស” សិស្សធ្វើជាអ្នកស៊ើបអង្កេតជំងឺគ្រុនឈាមនៅក្នុងសាលារៀន និងសហគមន៍របស់ខ្លួន |

## សារ

សារអប់រំសុខភាពអាចជាកត្តា ព័ត៌មាន ឬវិធានការដែលបានស្នើឡើង។ ពួកគេមានគោលបំណងពន្យល់ពីប្រធានបទសុខភាព (ជំងឺគ្រុនឈាម) និងបញ្ចុះបញ្ចូលទស្សនិកជនគោលដៅឲ្យរៀនសូត្រ កែប្រែ និងផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគេដោយស្ម័គ្រចិត្ត។

> សារអប់រំសុខភាពត្រូវតែ៖
>
> 1. ទាក់ទាញចំណាប់អារម្មណ៍ និងជំរុញឲ្យប្រជាជនធ្វើការផ្លាស់ប្តូរ
> 2. ទំនាក់ទំនងពីផលប្រយោជន៍សម្រាប់ទស្សនិកជន
> 3. ជ្រាបចូលដល់ខួរក្បាល (ព័ត៌មាន ចំណេះដឹង) និងដល់បេះដូង (អារម្មណ៍ ការជំរុញទឹកចិត្ត)

សារទាំងនេះគួរតែស្របនឹងគោលបំណងទំនាក់ទំនងសំខាន់មួយ – ការផ្លាស់ប្តូរទស្សនិកជនគោលដៅដែលមានគោលបំណងសម្រេចជាលទ្ធផលនៃទំនាក់ទំនង។

**តារាងទី២៖ សារស្តីពីចន្លោះពេលនៃការរាតត្បាតជំងឺ**

| | |
|---|---|
| **នៅពេលមានករណីជំងឺមិនទៀងទាត់** | គោលការណ៍ក្របខ័ណ្ឌការទំនាក់ទំនងជាយុទ្ធសាស្ត្ររបស់អង្គការសុខភាពពិភពលោក៖<br>• អាចចូលប្រើប្រាស់បាន<br>• អាចចាត់វិធានការបាន<br>• អាចទុកចិត្តបាន និងអាចជឿជាក់បាន<br>• ពាក់ព័ន្ធ<br>• ទាន់ពេលវេលា<br>• អាចយល់បាន |
| ព័ត៌មានទូទៅអំពីជំងឺគ្រុនឈាម និងហានិភ័យរបស់ជំងឺគ្រុនឈាម | |
| វិធានការកាត់បន្ថយផលប៉ះផលរបស់ជំងឺគ្រុនឈាម (ការគ្រប់គ្រង និងការទប់ស្កាត់ជំងឺគ្រុនឈាមនៅក្នុងសហគមន៍នានា) | |
| ការកៀរគរ និងការយល់ដឹងរបស់សហគមន៍ | |
| សារតស៊ូមតិសម្រាប់ជំងឺគ្រុនឈាម | |

**សូមមើលឧបសម្ព័ន្ធទី១** សម្រាប់បញ្ជីសារនានាដែលត្រូវប្រើប្រាស់ផ្អែកលើទស្សនិកជនគោលដៅ និងអាចសម្របទៅនឹងបរិបទ និងភាពចាំបាច់នានានៃស្ថានភាព។

សារទាំងនេះអាចប្រើប្រាស់សម្រាប់គោលបំណងផ្សេងៗ៖

- ចំណុចត្រូវនិយាយសម្រាប់អ្នកនាំពាក្យ
- សំណួរដែលសួរញឹកញាប់
- សម្ភារព័ត៌មាន ការអប់រំ និងទំនាក់ទំនង ដូចជា ផ្ទាំងផ្សព្វផ្សាយ ខិត្តប័ណ្ណ ស្ទីកឃ័រ ។ល។
- ប្រព័ន្ធផ្សព្វផ្សាយសង្គម ដូចជា Facebook និង Twitter
- សារសំខាន់សម្រាប់ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព
- សារសំខាន់សម្រាប់វគ្គផ្តល់ព័ត៌មានសហគមន៍
- សម្ភារសម្រាប់គេហទំព័រ
- សម្ភារវីដេអូ
- សម្ភារតស៊ូមតិ
- សារផ្ទាល់សម្រាប់កម្មវិធី SMS, WhatsApp, Viber, Messenger
- សារសំខាន់សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ

## បណ្ដាញទំនាក់ទំនង

ដើម្បីធ្វើឲ្យមានផលប៉ះពាល់ និងឈានដល់ចំនួនប្រជាជនគោលដៅ បណ្ដាញនិងបច្ចេកទេសដែលមានលាយគ្នាគួរតែត្រូវបានប្រើ។ មានចាប់ពីយុទ្ធសាស្ត្រទំនាក់ទំនងទល់មុខគ្នា ការប្រើឧបករណ៍បំពងសំឡេងនៅក្នុងសហគមន៍រហូតដល់ប្រព័ន្ធផ្សព្វផ្សាយសង្គម និងព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹង។ នេះនឹងពឹងផ្អែកទាំងធនធានដែលមាន និងអ្វីដែលជាវិធីល្អបំផុតដើម្បីឈានដល់ទស្សនិកជនគោលដៅ។ តារាងខាងក្រោមមិនមែនជាបញ្ជីជម្រើសទូលំទូលាយនោះទេ ជម្រើសទាំងអស់នោះគ្រាន់តែជាអនុសាសន៍ទូទៅមួយចំនួនប៉ុណ្ណោះ៖

| **ទស្សនិកជនគោលដៅ** | **បណ្ដាញដែលស្នើឡើង** |
|---|---|
| សាធារណជនទូទៅ | ប្រព័ន្ធផ្សព្វផ្សាយ (ទូរទស្សន៍ វិទ្យុ) ផ្ទាំងផ្សព្វផ្សាយនៅកន្លែងដែលគេទៅលេងញឹកញាប់ ដូចជា ផ្សារ វត្តអារាម ជាដើម<br>ឧបករណ៍បំពងសំឡេងនៅក្នុងសហគមន៍<br>បដា<br>ប្រព័ន្ធផ្សព្វផ្សាយសង្គម<br>គេហទំព័ររបស់ក្រសួងសុខាភិបាល |
| អ្នកថែទាំកុមារតូចៗ | វីដេអូនៅមណ្ឌលសុខភាព និងឱសថស្ថាននានា (ប្រសិនបើមានទូរទស្សន៍) ប័ណ្ណ ឬស្ទីគយ័រវំព្រកដែលត្រូវចែកចាយនៅមណ្ឌលសុខភាព និងសាលារៀន<br>ប្រព័ន្ធផ្សព្វផ្សាយសង្គម (ដូចជា Facebook)<br>វគ្គអប់រំនៅក្នុងមណ្ឌលសហគមន៍នានា<br>សារវីដេអូខ្លីៗផ្ញើតាមសេវាផ្ញើសារភ្លាមៗ ឬកម្មវិធី SMS |
| **អាជ្ញាធរក្នុងស្រុក និងអ្នកមានឥទ្ធិពលក្នុងសហគមន៍** | វគ្គអប់រំ និងសិក្ខាសាលា<br>សំណួរ និងចម្លើយអំពីជំងឺគ្រុនឈាម<br>ព្រឹត្តិការណ៍សម្អាតសហគមន៍ និងការលុបបំបាត់ជម្រកមូស (ដូចជាទិវាជំងឺគ្រុនឈាម)<br>ទំនាក់ទំនងផ្ទាល់ – ជួបផ្ទាល់ តាមទូរសព្ទ អ៊ីមែល WhatsApp |

| | |
|---|---|
| អ្នកធ្វើការសម្រេចចិត្តរបស់ក្រសួងសុខាភិបាល និងភាគីពាក់ព័ន្ធ | សំណួរ និងចម្លើយអំពីជំងឺគ្រុនឈាម<br>គេហទំព័ររបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រសម្រាប់ការទប់ស្កាត់ និងការគ្រប់គ្រងជំងឺគ្រុនឈាម<br>ទំនាក់ទំនងផ្ទាល់ – ជួបផ្ទាល់ តាមទូរសព្ទ អ៊ីមែល WhatsApp |
| អ្នកធ្វើគោលនយោបាយ | ការនិយាយរឿង -វីដេអូអំពីស្ថានភាពជំងឺគ្រុនឈាមពីសហគមន៍ដើម្បីលើកកម្ពស់ការយល់ដឹង<br>ការបោះពុម្ពផ្សាយអំពីមេរៀនទទួលបានពីជំងឺគ្រុនឈាម (ករណីសិក្សា រឿងជោគជ័យនានា)<br>ករណីវិនិយោគ<br>ព្រឹត្តិការណ៍នានាដើម្បីចែករំលែកបទពិសោធន៍<br>ទំនាក់ទំនងផ្ទាល់ – ជួបផ្ទាល់ តាមទូរសព្ទ អ៊ីមែល WhatsApp |
| ទីកន្លែងសាលារៀន | យុទ្ធសាស្ត្រកម្សាន្តអប់រំ (ការតាំងផ្ទាំងគំនូរ សំណួរ ល្បែង អំពីរបៀបដឹងពីជម្រកមូស គំនូរលើកង់ឡាន អ្នកស៊ើបអង្កេតជំងឺគ្រុនឈាម ជាដើម )<br>ការប្រកួតតែងសេចក្ដីៈ រឿងអំពីជំងឺគ្រុនឈាម<br>វគ្គអប់រំសម្រាប់អាជ្ញាធរសាលារៀន |

តំណភ្ជាប់ទៅនឹងសម្ភារដែលមានស្រាប់
នឹងធ្វើបច្ចុប្បន្នភាព

## ផ្នែកទី២ៈ ទំនាក់ទំនងហានិភ័យ

ជំងឺគ្រុនឈាមរួមជាមួយជំងឺឆ្លងផ្សេងៗ និងគ្រោះមហន្តរាយធម្មជាតិ គឺជាបញ្ហាសុខភាពសាធារណៈដ៏ធំមួយនៅក្នុងប្រទេសកម្ពុជា។ ដោយសារមូសចម្លងជំងឺគ្រុនឈាមកំពុងតែរីករាលដាលដល់ប្រទេសកម្ពុជា លទ្ធភាពនៃការផ្ទុះឡើងនៃជំងឺគឺខ្ពស់។ រដូវវស្សាដែលអូសបន្លាយពេលយូរ នគរូបនីយកម្មយ៉ាងឆាប់រហ័ស

ការប្រែប្រួលអាកាសធាតុ និងកត្តាបរិស្ថានដទៃទៀតកំពុងរួមចំណែកដល់ការរីករាលដាលនូវមេរោគជំងឺគ្រុនឈាម។

ទំនាក់ទំនងហានិភ័យត្រូវបានគេទទួលស្គាល់ថា ជាផ្នែកមួយនៃធាតុផ្សំសំខាន់ៗក្នុងការឆ្លើយតបប្រកបដោយជោគជ័យចំពោះការផ្ទុះឡើងនៃជំងឺគ្រុនឈាម។ វាគឺជាការផ្លាស់ប្តូរព័ត៌មាន និងយោបល់ទៅវិញទៅមករវាងបុគ្គល សហគមន៍ ស្ថាប័នទាក់ទងនឹងហានិភ័យនាពេលបច្ចុប្បន្ន ឬហានិភ័យដែលអាចកើតមានចំពោះសុខភាព ឬបរិស្ថានរបស់ពួកគេ។ ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពក្នុងពេលផ្ទុះឡើងនៃជំងឺ និងគ្រោះអាសន្នជំរុញឲ្យមានការប្រើប្រាស់នូវវិធានការទប់ស្កាត់ និងគ្រប់គ្រងដែលសមស្រប។

ការផ្ទុះឡើងនៃជំងឺតម្រូវឲ្យមានការឆ្លើយតបដែលមានការសម្របសម្រួលយ៉ាងល្អនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន។ អ្នកចូលរួមទាំងអស់ត្រូវទាក់ទងគ្នាប្រកបដោយប្រសិទ្ធភាពជាមួយសាធារណជន ជាមួយអ្នកពាក់ព័ន្ធផ្សេងៗ និងប្រព័ន្ធផ្សព្វផ្សាយដើម្បីកសាង និងរក្សាការជឿទុកចិត្ត និងភាពជឿជាក់ បង្ហាញពីការយកចិត្តទុកដាក់ និងការយកចិត្តទុកដាក់ និងជំរុញឲ្យមានវិធានការទប់ស្កាត់។

គោលការណ៍ណែនាំស្តីពីទំនាក់ទំនងហានិភ័យ (អង្គការសុខភាពពិភពលោក ឆ្នាំ២០១៧)៖

1. បង្កើត និងរក្សានូវទំនុកចិត្ត
2. ទទួលស្គាល់ និងទាក់ទងទោះបីជាក្នុងភាពមិនច្បាស់លាស់ក៏ដោយ
3. សម្របសម្រួល
4. តម្លាភាព
5. មុនគេ លឿន និងញឹកញាប់ក្នុងទំនាក់ទំនងសាធារណៈ
6. ធ្វើឲ្យអ្នកទាំងឡាយដែលទទួលផលប៉ះពាល់មានភាពពាក់ព័ន្ធ និងចូលរួម
7. ប្រើប្រាស់វិធីសាស្ត្ររួម

## អ្នកសម្របសម្រួលទំនាក់ទំនងហានិភ័យ

កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម / មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ

តួនាទី៖

- សម្របសម្រួលសកម្មភាពទំនាក់ទំនងហានិភ័យនៅក្នុងក្រសួងសុខាភិបាល និងជាមួយដៃគូខាងក្រៅផ្សេងទៀត (ដូចជា អង្គការសុខភាពពិភពលោក អង្គការយូនីសេហ្វ)។
- រាយការណ៍រាល់សកម្មភាពទំនាក់ទំនងហានិភ័យនៃជំងឺគ្រុនឈាម

- រៀបចំសារសំខាន់អំពីស្ថានភាពជំងឺគ្រុនឈាមអំឡុងពេលផ្ទុះឡើងនៃជំងឺ
- រៀបចំចំណុចត្រូវនិយាយសម្រាប់អ្នកនាំពាក្យ
- ធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ និងធ្វើឲ្យប្រាកដថា សម្ភារ និងព័ត៌មានដែលមានទាំងអស់ទាន់សភាពការណ៍
- ទាក់ទងជាមួយនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងដើម្បីចែករំលែកសារនានាតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម
- ចែកចាយសម្ភារនានាដល់ថ្នាក់ខេត្ត
- ត្រួតពិនិត្យប្រសិទ្ធភាពសារនៃទំនាក់ទំនងហានិភ័យ សម្ភារ និងសកម្មភាពនានាដោយស្តាប់ រកពាក្យចចាមអារ៉ាម និងធ្វើបច្ចុប្បន្នភាពតាមការចាំបាច់
- រៀបចំនៅពេលចាំបាច់នូវការបណ្តុះបណ្តាលពីទំនាក់ទំនងហានិភ័យជំងឺគ្រុនឈាមសម្រាប់បុគ្គលិកទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត
- ធ្វើការវាយតម្លៃបន្ទាប់ពីការផ្ទុះឡើងនៃជំងឺ ឬការពិនិត្យឡើងវិញនូវការឆ្លើយតបនៃទំនាក់ទំនងហានិភ័យដើម្បីចាប់យកបទពិសោធន៍ដែលទទួលបានសម្រាប់ការផ្ទុះឡើងនៃជំងឺនៅពេលក្រោយ

## ភាគីពាក់ព័ន្ធផ្ទៃក្នុង

គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម

នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង

អនុគណៈកម្មការគ្លីនិក

ឃ្លាំងឱសថកណ្តាល

មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព

នាយកដ្ឋានសេវាមន្ទីរពេទ្យ

- ផ្តល់ធាតុចូលសម្រាប់សារ និងសម្ភារសម្រាប់ទស្សនិកជនគោលដៅជាក់លាក់ (បុគ្គលិកសុខាភិបាល សាលារៀន ភាគីពាក់ព័ន្ធ និងដៃគូជាដើម)
- ចែករំលែកព័ត៌មាន និងសម្ភារព័ត៌មាន ការអប់រំ និងទំនាក់ទំនងនៅលើវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមនានា
- ជាស់តឿនកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាមចំពោះការផ្តល់មតិត្រឡប់របស់សហគមន៍ណាមួយអំពីផលិតផលទំនាក់ទំនងហានិភ័យ ឬពីវត្តមាននៃការយល់ច្រឡំ ឬពាក្យចចាមអារ៉ាមមិនមានប្រយោជន៍

- ចូលរួម និងសហសម្របសម្រួលការបណ្តុះបណ្តាលអំពីទំនាក់ទំនងហានិភ័យ ដែលរៀបចំដោយ កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម
- ចែកចាយសារ និងសម្ភារនានាដល់ក្រុមឆ្លើយតបរហ័ស

## សមត្ថភាគីថ្នាក់ក្រោមជាតិ៖

មន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិ មណ្ឌលសុខភាព មូលដ្ឋានសុខាភិបាលទាំងអស់

អ្នកគ្រប់គ្រងជំងឺគ្រុនឈាមតាមខេត្ត

ក្រុមឆ្លើយតបរហ័ស

បុគ្គលិកជំងឺគ្រុនចាញ់តាមភូមិ

ក្រុមគាំទ្រជួយតាមភូមិ

តួនាទី៖

- ចែកចាយសម្ភារព័ត៌មាន ការអប់រំ និងទំនាក់ទំនងដល់មណ្ឌលសុខភាព សាលារៀន វត្តអារាម កន្លែងការងារ ជាដើម
- បណ្តុះបណ្តាលអ្នកមានឥទ្ធិពលនៅក្នុងសហគមន៍អំពីជំងឺគ្រុនឈាម
- ធ្វើសកម្មភាពការចូលរួមផ្អែកលើសហគមន៍

## អ្នកនាំពាក្យ៖

មានមនុស្សចំនួនបីនាក់ត្រូវបានតែងតាំងធ្វើជាអ្នកនាំពាក្យអំឡុងពេលផ្ទុះឡើងនៃជំងឺគ្រុនឈាម៖

រដ្ឋលេខាធិការក្រសួងសុខាភិបាល

នាយកនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ

នាយកនៃនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង

នាយកនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ ជាអ្នកនាំពាក្យសំខាន់ ប៉ុន្តែអាស្រ័យលើស្ថានភាព នាយកនៃនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងអាចមានតួនាទីគាំទ្រ។ ពីមួយពេលទៅមួយពេល អាជ្ញាធរសុខភាពខេត្តក៏អាចត្រូវបានកោះហៅឲ្យធ្វើជាអ្នកនាំពាក្យផងដែរ។ សម្រាប់មូលហេតុនេះ ពួកគេក៏គួរតែត្រូវបានបណ្តុះបណ្តាលអំពីរបៀបគ្រប់គ្រងទំនាក់ទំនងហានិភ័យ អំឡុងពេលផ្ទុះឡើងនៃជំងឺគ្រុនឈាមផងដែរ។

# នីតិវិធីប្រតិបត្តិការស្តង់ដារ



## ទស្សនិកជនគោលដៅ និងគោលបំណងទំនាក់ទំនងសំខាន់មួយ

| ទស្សនិកជនគោលដៅ | គោលបំណងទំនាក់ទំនង | គោលបំណងទំនាក់ទំនងសំខាន់មួយ – លទ្ធផលនៃទំនាក់ទំនងរបស់យើង |
|---|---|---|
| **សាធារណជនទូទៅ** | ផ្តល់ព័ត៌មាននាពេលបច្ចុប្បន្នអំពីស្ថានភាព និងសារនានាអំពីទីកន្លែង និងពេលវេលាក្នុងការស្វែងរកការព្យាបាល | សមាជិករបស់សហគមន៍ស្វែងរកការព្យាបាលជំងឺគ្រុនឈាមចំកន្លែងត្រូវពេលវេលា |
| **អ្នកថែទាំទារក និងកុមារ** | ផ្តល់ព័ត៌មានអំពីរបៀបដឹងពីការទទួលស្គាល់ដំណាក់កាលដំបូងនៃរោគសញ្ញាជំងឺគ្រុនឈាម និងថាតើអ្វីត្រូវធ្វើប្រសិនបើកុមារឈឺដោយជំងឺគ្រុនឈាម | អ្នកថែទាំស្គាល់រោគសញ្ញាជំងឺគ្រុនឈាម និងសញ្ញាព្រមាននានាអំពីជំងឺគ្រុនឈាមធ្ងន់ធ្ងរ ហើយដឹងពីពេលវេលា និងទីកន្លែងត្រូវទៅរកការថែទាំសុខភាព |
| **អាជ្ញាធរក្នុងស្រុក និងអ្នកដឹកនាំសហគមន៍/អ្នកមានឥទ្ធិពលក្នុងសហគមន៍ក្នុងស្រុកដែលកំពុងតែបង្ហាញករណីជំងឺ** | ជំរុញ និងបញ្ចុះបញ្ចូលអាជ្ញាធរក្នុងស្រុក អ្នកដឹកនាំសហគមន៍ និងអ្នកមានឥទ្ធិពលក្នុងសហគមន៍ឲ្យដឹកនាំវិធានការកាត់បន្ថយជំងឺគ្រុនឈាមកម្រិតសហគមន៍ | អ្នកដឹកនាំសហគមន៍ និងអ្នកមានឥទ្ធិពលក្នុងសហគមន៍តស៊ូមតិ និងដឹកនាំវិធានការកាត់បន្ថយជំងឺគ្រុនឈាមក្នុងសហគមន៍ |
| **បុគ្គលិកសុខាភិបាល (វេជ្ជបណ្ឌិត និងគិលានុបដ្ឋាក គិលានុបដ្ឋាក** | ជូនដំណឹងបុគ្គលិកសុខាភិបាលអំពីស្ថានភាពជំងឺគ្រុនឈាម និងឲ្យពួកគេដឹងពីគោលការណ៍ណែនាំគ្លីនិកសម្រាប់ការគ្រប់គ្រងជំងឺគ្រុនឈាម | វេជ្ជបណ្ឌិតទាំងអស់នៅក្នុងផ្នែកសុខភាពព្យាបាលករណីជំងឺគ្រុនឈាមដែលត្រូវបានសង្ស័យ និងបានបញ្ជាក់ស្របតាមគោលការណ៍ណែនាំគ្លីនិក |

| | | |
|---|---|---|
| **គិលានុបដ្ឋាយិកា) នៅមូលដ្ឋានសុខាភិបាល** | ប្រើប្រាស់សិទ្ធិអំណាចរបស់បុគ្គលិកសុខាភិបាលជាអ្នកដែលមានឥទ្ធិពលដែលទទួលបានការទុកចិត្តនៅក្នុងសហគមន៍របស់ពួកគេ | បុគ្គលិកសុខាភិបាលអន្តរកម្មដោយភាពជឿជាក់ជាមួយនឹងអ្នកជំងឺអំឡុងពេលពិភាក្សាជុំវិញជំងឺគ្រុនឈាម។ នៅពេលបញ្ជូនអ្នកជំងឺទៅគេហដ្ឋាន ពួកគេផ្តល់ព័ត៌មានច្បាស់លាស់ពីរបៀបដែលពួកគេគួរទទួលបានការថែទាំនៅគេហដ្ឋាន។ |
| **ប្រព័ន្ធផ្សព្វផ្សាយ** | បង្កើតទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ និងផ្តល់ឲ្យប្រព័ន្ធផ្សព្វផ្សាយនូវព័ត៌មានត្រឹមត្រូវ និងផ្លូវការ និងសារនានាទៅកាន់សាធារណជន។ | បណ្តាញសារព័ត៌មានបញ្ជូនព័ត៌មានផ្លូវការដែលកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម និង/ឬក្រសួងសុខាភិបាលបានផ្តល់ដោយផ្ទាល់នោះ។ |

## សារ

ក្នុងគ្រាមានគ្រោះអាសន្នផ្នែកសុខភាព សាធារណជនអាចមានទុក្ខព្រួយយ៉ាងខ្លាំង ហើយការយល់ដឹង និងដំណើរការសារអាចមានការពិបាកខ្លាំងណាស់។ ប្រជាជននៅក្នុងស្ថានភាពនេះ ដំណើរការមធ្យោបាយផ្តល់ព័ត៌មានក្រោមកម្រិតសមត្ថភាពធម្មតា ឬកម្រិតអប់រំរបស់ពួកគេ ផ្តោតលើព័ត៌មានអវិជ្ជមានច្រើនជាងព័ត៌មានវិជ្ជមាន និងយកចិត្តទុកដាក់ច្រើនអំពីបញ្ហានៃការជឿទុកចិត្ត អត្ថប្រយោជន៍ យុត្តិធម៌ ការគ្រប់គ្រង និងកិច្ចការពារស្ថានភាព។

### <u>សារព្រៀក</u>

ដើម្បីផ្តល់នូវព័ត៌មានច្បាស់លាស់បំផុតសម្រាប់ទស្សនិកជនគោលដៅ វាមានសារសំខាន់ក្នុងការធ្វើឲ្យប្រាកដថា សារឆ្លើយតបទៅនឹងសំណួរខាងក្រោម៖

តើសារអាចយល់បានទេ?

- ☐ តើអ្នកបានចៀសវាងពាក្យបច្ចេកទេស និងភាសាបច្ចេកទេសឬទេ?
- ☐ តើផលិតផលទំនាក់ទំនងរបស់អ្នកត្រូវបានបកប្រែទៅជាភាសាក្នុងស្រុកបានត្រឹមត្រូវ (និងត្រូវបានពិនិត្យដោយអ្នកនិយាយភាសាដើម) ឬទេ?
- ☐ តើសារសមស្របសម្រាប់កម្រិតអប់រំរបស់ទស្សនិកជនគោលដៅឬទេ?

តើសារពេញលេញ ស្មោះត្រង់ និងបើកទូលាយឬទេ?

- ☐ តើអ្នកបានទទួលស្គាល់នូវភាពមិនច្បាស់លាស់ណាមួយឬទេ? មានន័យថា តើអ្នកបានទទួលស្គាល់ទាំងអ្វីដែលគេបានដឹង និងអ្វីដែលគេមិនបានដឹងឬទេ?
- ☐ តើអ្នកបានទំនាក់ទំនងនូវវិសាលភាពនៃបញ្ហា និងបានផ្តល់ដំណោះស្រាយឬទេ?

តើសារទាំងនេះពិចារណាពីការយល់ឃើញរបស់របស់ទស្សនិកជនគោលដៅអំពីហានិភ័យឬទេ ហើយតើសារទាំងនេះបង្ហាញថាអ្នកយកចិត្តទុកដាក់ឬទេ?

- ☐ តើអ្នកបានបង្ហាញពីការយល់ចិត្តឬទេ?
- ☐ ប្រសិនបើការយល់ឃើញពីហានិភ័យនៅទាប តើការផ្ញើសារនឹងធ្វើឲ្យមានការឆ្លើយតបអារម្មណ៍ឬទេ? ប្រសិនបើការយល់ឃើញពីហានិភ័យខ្ពស់ តើអ្នកបានដោះស្រាយក្តីកង្វល់របស់សហគមន៍ដោយការគោរពឬទេ?

តើសាររបស់អ្នកអាចចាត់វិធានការបានទេ ?

- ☐ តើប្រជាជនគោលដៅរបស់អ្នកអាចអនុវត្តវិធានការដែលអ្នកស្នើសុំឲ្យពួកគេអនុវត្តឬទេ?
- ☐ តើអ្នកបានពិចារណាថាតើអាចមានឧបសគ្គផ្នែកវប្បធម៌ សេដ្ឋកិច្ច (ដូចជា ការចំណាយ) ឬឧបសគ្គផ្សេងទៀតដែលអាចរារាំងក្រុមមួយចំនួនមិនឲ្យប្រើប្រាស់អាកប្បកិរិយា ដែលអ្នកកំពុងផ្សព្វផ្សាយនោះឬទេ?

សារត្រូវកែសម្រួលផ្អែកលើ៖

**ខ្លឹមសារ** – ត្រឹមត្រូវ ផ្អែកលើភស្តុតាង ច្បាស់លាស់ ពាក់ព័ន្ធ និងផ្តោតលើទស្សនិកជនគោលដៅ

**បរិបទ** – វប្បធម៌ ជំនឿ ការយល់ឃើញ ចំណេះដឹង ភាពចាំបាច់របស់ទស្សនិកជនគោលដៅ

**បណ្តាញ** – វិធីសាស្រ្តបញ្ជូនសារ៖ ប្រព័ន្ធផ្សព្វផ្សាយប្រពៃណី ប្រព័ន្ធផ្សព្វផ្សាយសង្គម គេហទំព័រ ទំនាក់ទំនងផ្ទាល់ ជាដើម

**ទំនាក់ទំនង** – ភាពអាណិតអាសូរ ការខ្វល់ខ្វាយ ការយោគយល់ ការគោរព ទំនុកចិត្ត ភាពស្មោះត្រង់ ការចូលរួម

សារជំងឺគ្រុនឈាមសម្រាប់ការផ្ទុះឡើងនៃជំងឺចាំបាច់ត្រូវមានលក្ខណៈជាក់លាក់ចំពោះស្ថានភាព ប៉ុន្តែក៏គាំទ្រសារដែលត្រូវបានប្រើក្នុងរដូវកាលមានជំងឺគ្រុនឈាមកម្រិតទាបក្នុងដំណាក់កាលអប់រំសុខភាព។ សូមមើលឧបសម្ព័ន្ធ X សម្រាប់សារក្នុងពេលមានការផ្ទុះឡើងនៃជំងឺ។

តារាងទី៣៖ សារស្តីពីការផ្ទុះឡើងនៃជំងឺគ្រុនឈាម

| **ស្ថានភាពនៃការផ្ទុះឡើងនៃជំងឺ** |
| --- |
| ស្ថានភាពជំងឺគ្រុនឈាមនាពេលបច្ចុប្បន្ន រួមមាន វិធានការនានារបស់រាជរដ្ឋាភិបាល |
| រោគសញ្ញាជំងឺគ្រុនឈាម និងសញ្ញាព្រមាន ស្វែងរកការថែទាំសុខភាពដំណាក់កាលដំបូង |
| ការថែទាំលំនៅឋានសម្រាប់អ្នកជំងឺគ្រុនឈាម |
| ការលុបបំបាត់ជម្រកមូស |

## បណ្តាញទំនាក់ទំនង

ចំពោះការអប់រំសុខភាព ដើម្បីកំណត់បណ្តាញទំនាក់ទំនងមានអនុសាសន៍ឲ្យធ្វើការវាយតម្លៃប្រភេទខ្លះនៃទស្សនិកជនគោលដៅ។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងស្ថានភាពមានការផ្ទុះឡើងនៃជំងឺមួយប្រហែលជាមិនមានពេលវេលាដើម្បីធ្វើការសិក្សា KAP ការស្ទង់មតិ ជាដើម។ ការវិភាគពីការយល់ឃើញពីហានិភ័យយ៉ាងឆាប់រហ័សអាចត្រូវបានអនុវត្តដោយផ្អែកលើព័ត៌មានក្រៅផ្លូវការ (ដូចជា ការត្រួតពិនិត្យប្រព័ន្ធផ្សព្វផ្សាយសង្គម ការត្រួតពិនិត្យប្រព័ន្ធផ្សព្វផ្សាយ សំណួរដែលមានតាមរយៈប្រព័ន្ធទូរសព្ទបន្ទាន់ Hotlines ព័ត៌មានពីវិស័យនេះ) និងការស្រាវជ្រាវស៊ីជម្រៅបន្ថែមទៀតត្រូវបានធ្វើឡើងនៅក្នុងរដូវកាលមានជំងឺគ្រុនឈាមកម្រិតទាប។

ក្នុងពេលមានគ្រោះអាសន្ន និងការផ្ទុះឡើងនៃជំងឺផ្អែកលើស្ថានភាព (ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ស្រុក) ការរួមបញ្ចូលគ្នានៃបណ្តាញដែលអាចទៅដល់ប្រជាជនបានលឿនត្រូវបានណែនាំបំផុត( ទូរទស្សន៍

វិទ្យុ ប្រព័ន្ធផ្សព្វផ្សាយសង្គម)។ បណ្តាញដែលមានស្រាប់គួរតែត្រូវប្រើដើម្បីធ្វើឲ្យមានការចូលរួមរបស់សហគមន៍ពីរផ្លូវ។ អាជ្ញាធរគួរតែសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធដើម្បីធានាថា ការផ្ញើសារមានភាពស៊ីសង្វាក់គ្នានៅគ្រប់នាយកដ្ឋាន ក្រសួង និងដៃគូនានា។ ប្រព័ន្ធផ្សព្វផ្សាយមិនអាចចៀសវាងបានទេ ដូច្នេះសេចក្តីប្រកាសព័ត៌មានជាទៀងទាត់ និងសន្និសីទសារព័ត៌មានគួរតែផ្តល់ព័ត៌មានថ្មីៗអំពីស្ថានភាព ចែករំលែកព័ត៌មានស្តីពីការឆ្លើយតបសកម្មភាពរបស់រដ្ឋាភិបាល និងអំពាវនាវឲ្យមានវិធានការកាត់បន្ថយផលប៉ះពាល់នៃការផ្ទុះឡើងនៃជំងឺ។

| ទស្សនិកជនគោលដៅ | បណ្តាញដែលស្នើឡើង |
| --- | --- |
| **សាធារណជនទូទៅ** | ប្រព័ន្ធផ្សព្វផ្សាយ (ទូរទស្សន៍ វិទ្យុ)<br>ឧបករណ៍បំពងសំឡេងនៅក្នុងសហគមន៍<br>បដា<br>ប្រព័ន្ធផ្សព្វផ្សាយសង្គម<br>សារ SMS ឬតាមសេវាផ្ញើសាររហ័ស<br>រូបភាពព័ត៌មានដែលមានសារសំខាន់<br>វគ្គព័ត៌មានសហគមន៍ |
| **អ្នកថែទាំកុមារតូចៗ** | វីដេអូនៅមណ្ឌលសុខភាព និងឱសថស្ថាននានា (ប្រសិនបើមានទូរទស្សន៍)<br>ប្រព័ន្ធផ្សព្វផ្សាយសង្គម (ដូចជា Facebook)<br>សារវីដេអូខ្លីៗផ្ញើតាមសេវាផ្ញើសាររហ័ស ឬកម្មវិធី SMS<br>សាររំឭកពីរោគសញ្ញា និងសញ្ញាព្រមាន និងអ្វីដែលត្រូវធ្វើ<br>សកម្មភាពតាមសាលារៀន |
| **អាជ្ញាធរក្នុងស្រុក/អ្នកមានឥទ្ធិពលក្នុងសហគមន៍** | សារសំខាន់ផ្ញើតាមអ៊ីមែល និងសេវាផ្ញើសាររហ័ស<br>គេហទំព័រដែលមានព័ត៌មានអំពីជំងឺគ្រុនឈាម និងស្ថានភាព<br>វគ្គសហគមន៍<br>ការចុះទៅសហគមន៍ដែលរងផលប៉ះពាល់ដើម្បីពង្រឹងសកម្មភាពគ្រប់គ្រង និងទប់ស្កាត់ជំងឺគ្រុនឈាម |

| | |
|---|---|
| **បុគ្គលិកសុខាភិបាល** | គេហទំព័ររបស់ក្រសួងសុខាភិបាល/មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ៖ ការគ្រប់គ្រងជំងឺគ្រុនឈាមនិងសម្ភារការគ្រប់គ្រងគ្លីនិក សារសំខាន់សម្រាប់អ្នកជំងឺ សម្ភារព័ត៌មាន ការអប់រំ និងទំនាក់ទំនងគាំទ្រសម្រាប់គ្លីនិក។ ការរំឮកសារសំខាន់នៃការគ្រប់គ្រងគ្លីនិកសម្រាប់ជំងឺគ្រុនឈាមតាមរយៈ Whatsapp និងបណ្តាញសង្គមដទៃទៀត |
| **ប្រព័ន្ធផ្សព្វផ្សាយ** | ការប្រកាសព័ត៌មាន<br>សន្និសីទសារព័ត៌មាន<br>ប្រព័ន្ធផ្សព្វផ្សាយសង្គម (ដូចជា ការចែករំលែកចំនួនករណីជំងឺដែលត្រូវបានធ្វើបច្ចុប្បន្នភាព)<br>សំណួរ និងចម្លើយ នៅលើគេហទំព័ររបស់ក្រសួងសុខាភិបាល/មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ |

# គន្ថនិទ្ទេស


ក្រសួងសុខាភិបាល ផែនការសកម្មភាពជាតិសម្រាប់ការទប់ស្កាត់ និងគ្រប់គ្រងជំងឺគ្រុនឈាម និងជំងឺឆ្លងដោយសារសត្វល្អិតខាំ (ឆ្នាំ២០១៨ - ២០២០) ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨

ក្រសួងសុខាភិបាល និងសេវាប្រជាពលរដ្ឋរបស់សហរដ្ឋអាមេរិក វិទ្យាស្ថានជាតិសុខភាព វិទ្យាស្ថានជាតិជំងឺមហារីក ធ្វើការងារកម្មវិធីទំនាក់ទំនងសុខភាពសហរដ្ឋអាមេរិក ឆ្នាំ២០១៣

អង្គការសុខភាពពិភពលោក ផែនការសកម្មភាពតំបន់ប៉ាស៊ីហ្វិកខាងលិចសម្រាប់ការគ្រប់គ្រង និងទប់ស្កាត់ជំងឺគ្រុនឈាម (ឆ្នាំ២០១៦) ការិយាល័យប្រចាំតំបន់ប៉ាស៊ីហ្វិកខាងលិចរបស់អង្គការសុខភាពពិភពលោក ហ្វីលីពីន ឆ្នាំ២០១៦

អង្គការសុខភាពពិភពលោក / ការិយាល័យប្រចាំតំបន់ប៉ាស៊ីហ្វិកខាងលិច ក្របខ័ណ្ឌទំនាក់ទំនងយុទ្ធសាស្ត្រសម្រាប់អង្គការសុខភាពពិភពលោកនៅតំបន់ប៉ាស៊ីហ្វិកខាងលិច ហ្វីលីពីន ឆ្នាំ២០១៧

អង្គការសុខភាពពិភពលោក / ការិយាល័យប្រចាំតំបន់ប៉ាស៊ីហ្វិកខាងលិច យុទ្ធសាស្រ្តអាស៊ីប៉ាស៊ីហ្វិកសម្រាប់ជំងឺដែលកំពុងលេចចេញ និងគ្រោះអាសន្នផ្នែកសុខភាពសាធារណៈ (APSED) ការជំរុញការអនុវត្តលើបទបញ្ញាសុខភាពអន្តរជាតិ (ឆ្នាំ២០០៥) ហ្វីលីពីន ឆ្នាំ២០១៧

អង្គការសុខភាពពិភពលោក ទំនាក់ទំនងសម្រាប់ផលប៉ះពាល់អាកប្បកិរិយា (COMBI) ៖ ឯកសារណែនាំសម្រាប់ទំនាក់ទំនង និងអាកប្បកិរិយាសង្គមក្នុងការឆ្លើយតបការផ្ទុះឡើងនៃជំងឺ ឆ្នាំ២០១២

អង្គការសុខភាពពិភពលោក ទំនាក់ទំនងហានិភ័យក្នុងគ្រោះអាសន្នផ្នែកសុខភាពសាធារណៈ៖ គោលការណ៍ណែនាំសម្រាប់គោលនយោបាយ និងការអនុវត្តនូវទំនាក់ទំនងហានិភ័យគ្រោះអាសន្ន ឆ្នាំ២០១៨។

## បញ្ជីធនធាន

ធនធានទំនាក់ទំនងហានិភ័យ

https://www.who.int/ihr/publications/risk_communications/en/

ក្របខ័ណ្ឌទំនាក់ទំនងយុទ្ធសាស្រ្តសម្រាប់ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព

https://www.who.int/mediacentre/communication-framework.pdf

ធនធានផ្សព្វផ្សាយសង្គម

https://www.thensmc.com/sites/default/files/Big_pocket_guide_2011.pdf

# ឧបសម្ព័ន្ធទី១៖ សារស្តីពីជំងឺគ្រុនឈាម

## សារស្តីពីចន្លោះរយៈពេលផ្ទុះឡើងនៃជំងឺ

*អាកប្បកិរិយាការពារ និងគ្រប់គ្រងសត្វល្អិតចម្លងមេរោគ*

ព័ត៌មានទូទៅស្តីពីជំងឺគ្រុនឈាម និងហានិភ័យរបស់ជំងឺគ្រុនឈាម

| សារសំខាន់ | សារគាំទ្រ |
|---|---|
| **ជំងឺគ្រុនឈាមគឺជាជំងឺដែលបណ្តាលមកពីមូសដែលកំពុងរីករាលដាលយ៉ាងឆាប់រហ័សជាមួយនឹងសក្តានុពលនៃការរីករាលដាលឥតឈប់ឈរ។** | វត្តមានជាសាកលនៃមេរោគជំងឺគ្រុនឈាមបានកើនឡើងយ៉ាងខ្លាំងនៅក្នុងប៉ុន្មានទសវត្សកន្លងមកនេះ។ |
| | ច្រើនជាងពាក់កណ្តាលនៃចំនួនប្រជាជននៅលើពិភពលោកគឺមានហានិភ័យក្នុងការកើតមានជំងឺ។ |
| | វាជាបញ្ហាសុខភាពដ៏ធំមួយនៅទូទាំងតំបន់ត្រូពិក និងតំបន់ត្រូពិកក្រោមរបស់ពិភពលោក ជាពិសេសនៅតំបន់ទីក្រុង និងពាក់កណ្តាលទីក្រុង។ |
| **ជំងឺគ្រុនឈាមគឺជាការឆ្លងមេរោគដែលចម្លងដោយមូស។** | វាត្រូវបានចម្លងដោយមូសញីខាំចម្លងមេរោគឆ្លង ជាពិសេសគឺមូស Aedes Aegypti។ |
| | មូសអាចចម្លងមេរោគពីមនុស្សដែលឆ្លងមេរោគ ហើយករណីភាគច្រើនមិនមានបង្ហាញរោគសញ្ញានៃជំងឺណាមួយទេ។ |
| | ម្តងម្កាល ជំងឺគ្រុនឈាមអាចវិវឌ្ឍទៅជាផលវិបាកដែលអាចបណ្តាលឲ្យស្លាប់ដែលហៅថាជាជំងឺគ្រុនឈាមធ្ងន់ធ្ងរ។ |
| **ដោយសារតែវត្តមានប្រចាំនៃមូស Aedes Aegypti នៅក្នុងប្រទេសរបស់យើងនោះមេរោគគ្រុនឈាមគឺរាតត្បាត។** | វាជាមូសក្នុងគ្រួសារដែលរស់នៅក្បែរតំបន់ទីក្រុង ហើយអាចកកើតនៅក្នុងកន្លែងដក់ទឹកណាមួយ។ សូម្បីតែគម្របដបក៏មានទឹកគ្រប់គ្រាន់សម្រាប់មូសញីពងដាក់បានដែរ។ |
| | មូសញីមានសកម្មភាពខ្លាំងបំផុតនៅពេលព្រឹកព្រលឹម (ម៉ោង ៦-៨ ព្រឹក) និងពេលរសៀល (៣-៨ ល្ងាច) ដែលធ្វើឲ្យរយៈពេលទាំងនេះមានហានិភ័យខ្ពស់បំផុតសម្រាប់មូសខាំ៖ ទោះយ៉ាងណាក៏ដោយ មូសញីដែលត្រូវការបន្តរកចំណីនឹងស្វែងរកប្រភពឈាមនៅពេលណាមួយ។ |
| | មូស Aedes Aegypti ពងរៀងរាល់ ៣-៤ ថ្ងៃម្តង នៅក្នុងសម្ភារស្តុកទឹកផ្សេងៗជាពិសេសនៅក្នុងប្រហោង ស្នាមប្រេះ និងក្រហូងបិទបាំងនានាដែល |

| | |
|---|---|
| | ជានាថាកូនចៅរបស់វាគឺពិបាកបំផ្លាញណាស់សូម្បីតែទឹកទាំងអស់ត្រូវបានយកចេញក៏ដោយ។ |
| | មូសចម្លងមេរោគអាចដាក់ពងដែលផ្ទុកមេរោគគ្រុនឈាមរួចហើយនឹងក្លាយជាមូសពេញវ័យចម្លងមេរោគជំងឺនេះ។ ក្នុងករណីនោះ មិនចាំបាច់ខាំមនុស្សជាមុនដើម្បីចម្លងមេរោគនោះទេ។ |
| **ជំងឺគ្រុនឈាមគឺជាកង្វល់ផ្នែកសុខភាពសាធារណៈដ៏ធំមួយសម្រាប់ប្រទេសកម្ពុជា។** | ជំងឺគ្រុនឈាមគឺជាបុព្វហេតុចំបងមួយនៃជំងឺធ្ងន់ធ្ងរ និងមរណភាពក្នុងចំណោមកុមារ និងមនុស្សពេញវ័យនៅក្នុងប្រទេស និងតំបន់របស់យើង។ |
| | មេរោគគ្រុនឈាមមាន ៤ប្រភេទ។ ការឆ្លង និងជាសះស្បើយពីប្រភេទមេរោគមួយមិនផ្តល់ភាពស៊ាំសម្រាប់ប្រភេទផ្សេងទៀតទេ៖ ការឆ្លងជំងឺជាបន្តបន្ទាប់ដោយប្រភេទមេរោគផ្សេងទៀតអាចបណ្តាលឲ្យមានជំងឺគ្រុនឈាមធ្ងន់ធ្ងរ។ |
| | ការឆ្លងមេរោគនេះបណ្តាលឲ្យមានជំងឺដូចជំងឺផ្តាសាយ ហើយជារឿយៗអាចច្រឡំជាមួយជំងឺដទៃទៀតដែលបង្ហាញរោគសញ្ញាស្រដៀងគ្នា។ ជាលទ្ធផល ការធ្វើរោគវិនិច្ឆ័យអាចជាបញ្ហាប្រឈមមួយ។ មានតែការធ្វើតេស្តនៅមន្ទីរពិសោធន៍ប៉ុណ្ណោះដែលអាចបញ្ជាក់ពីវត្តមានមេរោគនេះបាន។ |
| | ប្រហែលជាប្រជាជន ១នាក់ ក្នុងចំណោម ៤នាក់ ដែលឆ្លងមេរោគគ្រុនឈាមនឹងបង្ហាញរោគសញ្ញា។ ទោះជាយ៉ាងណាក៏ដោយ ពួកគេគឺជាអ្នកផ្ទុកមេរោគគ្រុនឈាម ហើយអាចចម្លងមេរោគបានប្រសិនបើត្រូវមូសខាំ។ |
| **នៅពេលឆ្លងមេរោគជំងឺគ្រុនឈាម មនុស្សខ្លះមិនអាចបង្ហាញរោគសញ្ញាបានទេ ខណៈអ្នកផ្សេងទៀតអាចវិវឌ្ឍយ៉ាងលឿនទៅជាជំងឺធ្ងន់ធ្ងរ ឬរហូតដល់ស្លាប់។** | នៅពេលចាប់ផ្តើមមានជំងឺ គ្រុនក្តៅខ្លាំង (៤០ °C / ១០៤ °F) គឺជារោគសញ្ញាញឹកញាប់បំផុតអមដោយយ៉ាងហោចណាស់ពីររោគសញ្ញា ដូចខាងក្រោមនេះ៖ ឈឺក្បាលធ្ងន់ធ្ងរ ឈឺនៅខាងក្រោយភ្នែក ឈឺ ក្អួតមានអារម្មណ៍ខ្សោយ ឈឺសាច់ដុំ និងសន្លាក់ ក្រពេញហើម ឬកន្ទួលក្រហមៗលើស្បែក។ |
| | រោគសញ្ញាជាធម្មតាចាប់ផ្តើមពី ៤-១០ ថ្ងៃបន្ទាប់ពីមូសដែលមានមេរោគខាំហើយជាធម្មតាមានរយៈពេល ២-៧ ថ្ងៃ។ |
| | ប្រសិនបើអ្នក ឬអ្នកជាទីស្រឡាញ់របស់អ្នកធ្លាប់មានរោគសញ្ញាដែលបានរៀបរាប់ពីមុន សូមរកមើលការថែទាំសុខភាពនៅក្នុងគ្លីនិកសុខភាពរបស់អ្នក។ |
| | ជំងឺគ្រុនឈាមអាចត្រូវបានបញ្ជាក់ដោយការធ្វើតេស្តមន្ទីរពិសោធន៍។ វេជ្ជបណ្ឌិតនៅគ្លីនិកសុខភាពនឹងស្នើសុំការធ្វើតេស្តមន្ទីរពិសោធន៍ជាក់លាក់។ |

| | |
|---|---|
| **ប្រសិនបើអ្នក ឬមនុស្សជាទីស្រឡាញ់របស់អ្នកជួបប្រទះនូវសញ្ញាព្រមាននៃជំងឺគ្រុនឈាមធ្ងន់ធ្ងរ សូមទៅមន្ទីរពេទ្យជាបន្ទាន់។** | សញ្ញាព្រមាននៃជំងឺគ្រុនឈាមធ្ងន់ធ្ងរកើតឡើង ៣-៧ ថ្ងៃបន្ទាប់ពីមានរោគសញ្ញាដំបូង ហើយទាក់ទងនឹងការថយចុះសីតុណ្ហភាព (ក្រោម ៣៨ ◦C / ១០០ ◦F) និងរួមមាន៖ ឈឺក្រពះធ្ងន់ធ្ងរ ក្អួតជាប់រហូត ដកដង្ហើមញាប់អញ្ចាញធ្មេញហូរឈាម អស់កម្លាំង ការមិនស្រួលខ្លួន និងមានឈាមពេលក្អួត។ |
| | នៅពេលដែលមានសញ្ញាព្រមានត្រូវបានបង្ហាញមក ពេលវេលាគឺសំខាន់ណាស់។ ត្រូវទៅមន្ទីរពេទ្យភ្លាម។ |
| | ទារក និងកុមារតូចៗងាយនឹងរងគ្រោះដោយសារជំងឺគ្រុនឈាមបំផុត។ ប្រសិនបើក្មេងអាយុក្រោម១៨ខែ មានគ្រុនក្តៅខ្លាំងនៅក្នុងតំបន់គ្រុនឈាម វាមានសារសំខាន់បំផុតក្នុងការស្វែងរកថែទាំសុខភាព។ |
| | មិនត្រូវប្រើថ្នាំណាមួយមុនពេលពិគ្រោះជាមួយវេជ្ជបណ្ឌិតឡើយ។ |
| **មិនមានការព្យាបាលជាក់លាក់ណាមួយសម្រាប់ជំងឺគ្រុនឈាមទេ។** | ករណីស្រាលៗ នឹងត្រូវបានព្យាបាលនៅលំនៅឋានដើម្បីឲ្យធូរស្បើយពីគ្រុនក្តៅ ឈឺក្បាល ឈឺ និងចុកសាច់ដុំ និងសន្លាក់ដោយថ្នាំប៉ារ៉ាសេតាម៉ុល ដោយសម្រាក និងផឹកទឹកឲ្យបានច្រើន។ |
| | ករណីធ្ងន់ធ្ងរត្រូវការព្យាបាលនៅមន្ទីរពេទ្យជាបន្ទាន់ និងការព្យាបាលវេជ្ជសាស្ត្រជាក់លាក់។ |
| | អ្នកជំងឺភាគច្រើននឹងមានអារម្មណ៍ធូរស្រាលបន្ទាប់ពី ១០-១៤ ថ្ងៃហើយនឹងជាសះស្បើយទាំងស្រុង។ |

## វិធានការនានាដើម្បីកាត់បន្ថយផលប៉ះពាល់របស់ជំងឺគ្រុនឈាម

| <u>សារសំខាន់</u> | <u>សារគាំទ្រ</u> |
|---|---|
| **ការកាត់បន្ថយជម្រកមូសគឺជាវិធីដែលមានប្រសិទ្ធភាពបំផុតក្នុងការការពារបុគ្គល និងសហគមន៍ពីជំងឺគ្រុនឈាម។** | គ្មានមូសគឺគ្មានជំងឺគ្រុនឈាម |
| | ការទប់ស្កាត់មូសមិនឲ្យបង្កាត់ពូជ និងខាំគឺជាវិធានការការពារដ៏ល្អបំផុត |
| | ការខិតខំបាញ់ថ្នាំគឺមិនគ្រប់គ្រាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងមូសទេ។ |
| **ការកំណត់អត្តសញ្ញាណ ការសម្អាត និងការបំផ្លាញជម្រក** | អ្វីៗគ្រប់យ៉ាងដែលអាចដក់ទឹកបានអាចជាជម្រកមូស។ វត្ថុដក់ទឹកតូចប៉ុននឹងគម្របដបក៏អាចជាកន្លែងមូសពងបានដែរ។ |

| | |
|---|---|
| **មូសនឹងជួយកាត់បន្ថយការឆ្លងជំងឺគ្រុនឈាមនៅក្នុងសហគមន៍។** | ដើម្បីទប់ស្កាត់មូសមិនឲ្យមានកើតមានក្នុងគ្រួសារ និងសហគមន៍៖<br>• សម្អាតកាកសំណល់ និងសំរាមជុំវិញរបស់អ្នកដែលអាចដក់ទឹកបាន<br>• ប្រសិនបើមានសម្បកកង់នៅលើអចលនទ្រព្យរបស់អ្នក សូមពិនិត្យមើលថាមិនមានទឹកដក់ខាងក្នុងទេ។ បើអាចធ្វើបាន សូមទុកសម្បកកង់ឡាននៅកន្លែងដែលគ្របជិត។<br>• យ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍ ប្តូរទឹកនៅក្នុងថូ និងផើងផ្កា និងថាសទម្រុក្ខជាតិ ឬរបស់របរផ្សេងទៀតដែលមានដក់ទឹក។<br>• ជានិច្ចកាល ត្រូវទុកទឹកក្នុងពាង ធុង និងក្រឡគ្របជិតដែលមានគម្របទប់ស្កាត់មូស។<br>• រាល់ធុង និងពាងស្តុកទឹកទាំងអស់គួរតែត្រូវបានសម្អាត លាង និងជូតចេញ (ជាពិសេសគែម និងទ្រ) ម្តងក្នុងមួយសប្តាហ៍ ដើម្បីយកពងមូសចេញ។<br>• ប្រសិនបើមានបំពង់ខូច ឬលេចធ្លាយទឹកនៅកន្លែងជុំវិញអ្នក ចូររាយការណ៍ទៅអាជ្ញាធរ។ (រួមបញ្ចូលបើដែលអាចមានទាំងព័ត៌មានលម្អិតអំពីវិធីរាយការណ៍ ដូចជាតាមរយៈលេខទូរសព្ទ ឬគេហទំព័រ)<br>• បង្ហូរទ-ទឹកលើដំបូល និងជានាថាទឹកដោយស្រួល<br>• រាយការណ៍ពីជម្រកមូសនៅក្នុងកន្លែងដែលគេបោះបង់ចោល កន្លែងសាធារណៈ ទីធ្លាសួនកុមារ និងកន្លែងធ្វើការ។ (រួមបញ្ចូលបើដែលអាចមានទាំងព័ត៌មានលម្អិតអំពីវិធីរាយការណ៍ ដូចជាតាមរយៈលេខទូរសព្ទ ឬគេហទំព័រ)<br>• ទឹកនៅក្នុងពាងស្តុកទឹកធំ (រហូតដល់ ៣០០ លីត្រ) គួរតែត្រូវបានប្រព្រឹត្តកម្មដោយថ្នាំសម្លាប់ដង្កូវទឹកស្របតាមបទបញ្ជាអនាម័យដើម្បីសម្លាប់ដង្កូវ និងពងមូស។ (សត្វ Aedes មិនកកើតនៅក្នុងពាងទឹកដែលមានទំហំធំជាង ៣០០ លីត្រទេ។ )<br>• ប្រើសំណាញ់បង្អួច និងទ្វារ ប្រសិនបើអាច។ |

| | |
|---|---|
| | វាមិនគ្រប់គ្រាន់ទេគ្រាន់តែផ្ដាប់ពាងនិងបង្ហូរទឹកចោលប៉ុណ្ណោះ។ មូសអាចរស់បានក្នុងពាងទទេ និងស្ងួតរហូតដល់ ៦ខែ។ នៅពេលដែលប៉ះត្រូវនឹងទឹក នោះពងមូសញាស់ និងវដ្ដនៃជីវិតមូសចាប់ផ្ដើមម្ដងទៀត។ |
| **ដោយចាត់វិធានការការពារសាមញ្ញមួយចំនួន អ្នកអាចកាត់បន្ថយលទ្ធភាពនៃមូសខាំបាន។** | ការពារខ្លួនអ្នកដោយស្លៀកពាក់គ្របដណ្ដប់រាងកាយឲ្យបានជិតបំផុតតាមដែលអាចធ្វើទៅបាន ប្រើថ្នាំបណ្ដេញសត្វល្អិត និងសម្រាកនៅក្នុងមុងប្រសិនបើមានជំងឺគ្រុនឈាម។ |
| | ព្យាយាមស្នាក់នៅក្នុងលំនៅឋាន ជាពិសេសក្នុងអំឡុងម៉ោងពេលព្រឹកព្រលឹម និងពេលរសៀលនៅពេលដែលមូសមានសកម្មភាពខ្លាំងបំផុត ប្រសិនបើអាចនៅកន្លែងដែលមានម៉ាស៊ីនត្រជាក់។ |
| **នៅពេលថែរក្សាសមាជិកគ្រួសារដែលមានជំងឺ សូមចាត់វិធានការការពារជាមុនដើម្បីការពារសមាជិកគ្រួសារផ្សេងៗទៀតពីមូសខាំ។** | ក្នុងអំឡុងពេលមួយសប្ដាហ៍ដំបូងនៃការឆ្លង មេរោគគ្រុនឈាមគឺស្ថិតនៅក្នុងឈាមរបស់អ្នកដែលឆ្លងមេរោគ៖ ប្រសិនបើមូសខាំអ្នកនោះ មេរោគអាចចម្លងទៅអ្នកផ្សេងទៀតដែលនៅជុំវិញពួកគេបាន។ |
| | ប្រសិនបើមានការសង្ស័យថា សមាជិកគ្រួសារម្នាក់អាចឆ្លងជំងឺគ្រុនឈាម ឬកំពុងមានរោគសញ្ញា ត្រូវឲ្យគាត់សសម្រាក និងដេកនៅក្នុងមុងដើម្បីការពារសមាជិកគ្រួសារផ្សេងទៀតពីជំងឺគ្រុនឈាម។ |
| | ប្រសិនបើអ្នកសង្ស័យឬឮថា សមាជិកគ្រួសារ ឬអ្នកជិតខាងឈឺដោយសារជំងឺគ្រុនឈាម សូមពង្រឹងសកម្មភាពរបស់អ្នកដើម្បីលុបបំបាត់ជម្រកមូសនៅជុំវិញគ្រួសាររបស់អ្នក។ |
| | អ្នកឈឺត្រូវការសម្រាក ផឹកទឹកឲ្យបានច្រើន និងត្រូវបានព្យាបាលគ្រុនក្ដៅ និងការឈឺចាប់។ ប្រសិនបើពួកគេមានការផ្លាស់ប្ដូរសីតុណ្ហភាពភ្លាមៗ (ខ្ពស់ខ្លាំង ឬទាបខ្លាំង) ហើយរោគសញ្ញាកាន់តែធ្ងន់ធ្ងរទៅ សូមនាំពួកគេទៅមន្ទីរពេទ្យជាបន្ទាន់។ |
| **ការបាញ់ថ្នាំសម្លាប់មូស មិនគ្រប់គ្រាន់ក្នុងការបំផ្លាញមូសឡើយ។** | ខណៈពេលការបាញ់ថ្នាំសម្លាប់មូសអាចកាត់បន្ថយចំនួនមូសពេញវ័យជាបណ្ដោះអាសន្ន ថ្នាំសម្លាប់សត្វល្អិតមិនសម្លាប់ដង្កូវទឹក និងពងមូសទេ។ នោះហើយជាមូលហេតុ ដែលវាមានសារសំខាន់ផងដែរក្នុងការសម្អាតជម្រកមូស។ |

| | |
|---|---|
| | នៅពេលបាញ់ថ្នាំសម្លាប់មូស វាមានប្រយោជន៍ក្នុងការទុកបង្អួច និងទ្វារផ្ទះរបស់អ្នកឲ្យចំហដើម្បីឲ្យដំណក់ទឹកនិងសន្សើមចូលទៅខាងក្នុង និងសម្លាប់មូសពេញវ័យ។ |
| | អនុវត្តតាមការណែនាំរបស់អាជ្ញាធរ ក្នុងអំឡុងពេលធ្វើសកម្មភាពបាញ់ថ្នាំសម្លាប់មូស។ |

## ការយល់ដឹង និងការចូលរួមរបស់សហគមន៍ជំងឺគ្រុនឈាម

| <u>សារសំខាន់</u> | <u>សារគាំទ្រ</u> |
|---|---|
| **ការជូនដំណឹងអំពីជំងឺគ្រុនឈាមនិងស្គាល់សញ្ញានៃការឆ្លងដែលអាចកើតមាន ពិតជាមានសារសំខាន់ណាស់។** | ត្រូវដឹងពីស្ថានភាពជំងឺគ្រុនឈាមនៅក្នុងប្រទេស និងសហគមន៍របស់អ្នក។ |
| | ដឹងពីរោគសញ្ញា និងសញ្ញាព្រមាននៃជំងឺគ្រុនឈាម៖ ការរកឃើញដំណាក់កាលដំបូង និងការទទួលបានការថែទាំសុខភាពត្រឹមត្រូវមានសារសំខាន់ខ្លាំងណាស់ក្នុងការការពារពីផលវិបាក និងមរណភាព។ |
| | ប្រសិនបើអ្នកកំពុងធ្វើដំណើរទៅប៉ែកនានានៃប្រទេសដែលមានករណីជំងឺគ្រុនឈាម សូមអនុវត្តតាមព័ត៌មានដែលផ្ដល់ដោយអាជ្ញាធរហើយអនុវត្តវិធានការការពារផ្ទាល់ខ្លួនដែលបានណែនាំ។ |
| **អ្នកគ្រប់គ្នាមានតួនាទីក្នុងការទប់ស្កាត់ជំងឺគ្រុនឈាម។** | សកម្ម និងចូលរួមជាមួយសហគមន៍របស់អ្នកក្នុងការបំផ្លាញជម្រកមូស។ |
| | ចូលរួម និងលើកទឹកចិត្តដល់ការសម្អាតបរិស្ថានក្នុង និងខាងក្រៅលំនៅឋានដើម្បីលុបបំបាត់ និងកាត់បន្ថយអ្វីៗទាំងអស់ដែលអាចដក់ទឹកនៅក្នុងគ្រួសារ តំបន់ជុំវិញ សាលារៀន និងកន្លែងធ្វើការរបស់អ្នក។ |
| | ចូលរួមសកម្មភាពគ្រប់គ្រងសត្វល្អិតចម្លងមេរោគក្នុងសហគមន៍ និងប្រើប្រាស់ និងលើកកម្ពស់វិធានការការពារផ្ទាល់ខ្លួន។ |
| **ទោះបីជាការផ្ទុះឡើងនៃជំងឺគ្រុនឈាមមិនអាចចៀសវាង** | ជំងឺគ្រុនឈាមគឺជាជំងឺដ៏កាចសាហាវមួយដែលអាចបង្ការបានដោយការសម្អាត និងលុបបំបាត់ជម្រកមូស។ វិធានការទាំងនេះត្រូវធ្វើជា |

| | |
|---|---|
| **បានក៏ដោយ តាមរយៈការអនុវត្តវិធានការទប់ស្កាត់មូសប្រកបដោយនិរន្តរភាព នោះ ទំហំ ប្រេកង់និង ផលប៉ះពាល់នៃការផ្ទុះឡើងនៃជំងឺ អាចត្រូវបានកាត់បន្ថយយ៉ាងខ្លាំង។** | ប្រចាំម្តងក្នុងមួយសប្តាហ៍និងមាននិរន្តរភាពដើម្បីទប់ស្កាត់ការផ្ទុះឡើងនៃជំងឺ។ |
| | ស្ថានភាពនៃការផ្ទុះឡើងនៃជំងឺគឺជាបន្ទុកសេដ្ឋកិច្ច និងសង្គមយ៉ាងធំធេងសម្រាប់សហគមន៍ដែលរងផលប៉ះពាល់ អាជ្ញាធរមូលដ្ឋាន សេវាសុខភាព និងក្រុមគ្រួសារដែលត្រូវថែទាំអ្នកដែលមានជំងឺ។ |
| | ការរៀបចំ និងរៀបចំផែនការមុនការផ្ទុះឡើងនៃជំងឺគ្រុនឈាមអាចជួយសម្រួលដល់ការចាត់វិធានការរហ័ស ជួយសង្គ្រោះជីវិត និងកាត់បន្ថយបន្ទុកជំងឺគ្រុនឈាម។ |
| **បុគ្គល គ្រួសារ និងសហគមន៍ គឺជាអ្នកធ្វើការសម្រេចចិត្តអំពីសុខភាពរបស់ពួកគេ។** | ការរស់នៅក្នុងសហគមន៍ស្អាត មានការរៀបចំ និងការការពារនាំមកនូវគុណភាពជីវិតកាន់តែប្រសើរ និងកាត់បន្ថយហានិភ័យនៃជំងឺជាច្រើនរួមទាំងជំងឺគ្រុនឈាម។ |
| | អ្នកគ្រប់គ្នា - កុមារ និងមនុស្សពេញវ័យ - អាចចូលរួមក្នុងការលុបបំបាត់ជម្រកមូស។ នេះគឺជាវិធានការដែលមានទាំងប្រសិទ្ធភាពនិងមាននិរន្តរភាពបំផុតក្នុងការទប់ស្កាត់ជំងឺគ្រុនឈាម។ |
| | ធ្វើឲ្យអ្នកជិតខាងរបស់អ្នកចូលរួម ហើយកុំឲ្យជំងឺគ្រុនឈាមមាននៅក្នុងសហគមន៍របស់អ្នក។ |

# សារស្តីពីការផ្ទុះឡើងនៃជំងឺគ្រុនឈាម

ស្ថានភាពជំងឺគ្រុនឈាម

| <u>សារសំខាន់</u> | <u>សារគាំទ្រ</u> |
|---|---|
| **នាពេលបច្ចុប្បន្ន ប្រទេស / ខេត្ត កំពុងមានការផ្ទុះឡើងនៃជំងឺគ្រុនឈាម / ចំនួនករណីជំងឺគ្រុនឈាមខ្ពស់។** | សារត្រូវបង្កើតតាមប្រទេស<br>តើមានអ្វីកំពុងកើតឡើង?<br>• តើការផ្ទុះឡើងនៃជំងឺកំពុងកើតឡើងនៅកន្លែងណា?<br>• តើតួលេខករណីជំងឺនាពេលបច្ចុប្បន្នមានចំនួនប៉ុន្មាន? ប្រសិនបើមិនដឹង តើវាចាំបាច់ត្រូវតែនិយាយឬទេ?<br>• តើអ្វីខ្លះនៅតែមិនទាន់ដឹង ឬព័ត៌មានអ្វីខ្លះនៅខ្វះខាតនោះ? |

| | |
|---|---|
| | នៅពេលណាដែលនឹងមានព័ត៌មានបន្ថែមនោះ? |
| | អាជ្ញាធរសុខាភិបាលយល់ពីកង្វល់ (របស់ប្រជាជននៅតំបន់ដែលរងផលប៉ះពាល់) ហើយកំពុងធ្វើការដើម្បីកាត់បន្ថយស្ថានភាពនេះ។ (ពន្យល់ពីវិធានការដែលអាជ្ញាធរសុខាភិបាលបានអនុវត្ត) |
| | សូមចាំតាមដាន និងអនុវត្តតាម (គេហទំព័រក្រសួងសុខាភិបាល ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក ប្រព័ន្ធផ្សព្វផ្សាយសង្គម ....) សម្រាប់ព័ត៌មានទាន់ហេតុការណ៍។ |
| **ជំងឺគ្រុនឈាមគឺជាជំងឺឆ្លងមួយដែលបង្កឡើងដោយសត្វមូស។** | វាត្រូវបានចម្លងដោយសារមូសញីខាំ ជាពិសេសគឺ មូស Aedes Aegypti ។ |
| | មូសអាចចម្លងមេរោគពីមនុស្សដែលឆ្លងមេរោគហើយ ក្នុងករណីភាគច្រើនមិនមានបង្ហាញរោគសញ្ញាណាមួយនៃជំងឺទេ។ |
| | ជួនកាល ជំងឺគ្រុនឈាមអាចវិវឌ្ឍទៅជាផលវិបាកដ៏កាចសាហាវមួយដែលហៅថាជំងឺគ្រុនឈាមធ្ងន់ធ្ងរ។ |
| **រោគសញ្ញានៃជំងឺគ្រុនឈាមមានភាពខុសគ្នាជាច្រើន។ អ្នកខ្លះមិនអាចបង្ហាញរោគសញ្ញាបានទេ ខណៈពេលដែលសម្រាប់អ្នកផ្សេងទៀត រោគសញ្ញានេះអាចបណ្តាលឲ្យមានជំងឺធ្ងន់ធ្ងរ ឬរហូតដល់ទទួលមរណភាព។** | **នៅពេលចាប់ផ្តើមមានជំងឺ គ្រុនក្តៅខ្លាំង (៤០ អង្សាសេ / ១០៤ អង្សាហ្វារិនហាយ) គឺជារោគសញ្ញាញឹកញាប់បំផុតគួបផ្សំនឹងរោគសញ្ញាយ៉ាងហោចណាស់ពីរដូចខាងក្រោមនេះ៖ ឈឺក្បាលធ្ងន់ធ្ងរ ឈឺនៅខាងក្រោយភ្នែក ឈឺក្អួតមានអារម្មណ៍ខ្សោយ ឈឺសាច់ដុំ និងសន្លាក់ ក្រពេញហើម ឬកន្ទួលក្រហមៗលើស្បែក។** |
| | រោគសញ្ញាជាធម្មតាចាប់ផ្តើមពី ៤-១០ ថ្ងៃបន្ទាប់ពីមូសដែលមានមេរោគខាំ ហើយជាធម្មតាមានរយៈពេល ២-៧ ថ្ងៃ។ |
| | **ប្រសិនបើអ្នក ឬអ្នកជាទីស្រឡាញ់របស់អ្នកធ្លាប់មានរោគសញ្ញាដែលបានរៀបរាប់ពីមុន សូមរកមើលការថែទាំសុខភាពនៅក្នុងគ្លីនិកសុខភាពរបស់អ្នក។** |
| | ជំងឺគ្រុនឈាមអាចត្រូវបានបញ្ជាក់ដោយការធ្វើតេស្តមន្ទីរពិសោធន៍។ វេជ្ជបណ្ឌិតនៅគ្លីនិកសុខភាពនឹងស្នើសុំការធ្វើតេស្តមន្ទីរពិសោធន៍ជាក់លាក់។ |
| **ប្រយ័ត្នចំពោះសញ្ញាព្រមាននានា។ ប្រសិនបើអ្នក ឬមនុស្សជាទីស្រឡាញ់របស់អ្នកជួបប្រទះ** | សញ្ញាព្រមាននៃជំងឺគ្រុនឈាមធ្ងន់ធ្ងរកើតឡើង ៣-៧ ថ្ងៃបន្ទាប់ពីមានរោគសញ្ញាដំបូង ហើយទាក់ទងនឹងការថយចុះសីតុណ្ហភាព (ក្រោម ៣៨ អង្សាសេ / ១០០ អង្សាហ្វារីណហាយ) និងរួមមាន៖ ឈឺក្រពះធ្ងន់ធ្ងរ ក្អួតជាប់ |

| | |
|---|---|
| **នូវសញ្ញាព្រមាននៃជំងឺគ្រុនឈាមធ្ងន់ធ្ងរ សូមទៅមន្ទីរពេទ្យជាបន្ទាន់។** | រហូត ដកដង្ហើមញាប់ អញ្ចាញធ្មេញហូរឈាម អស់កម្លាំង ការមិនស្រួលខ្លួន និងមានឈាមពេលក្អួត។ |
| | ២៤-៤៨ ម៉ោងដំបូងគឺសំខាន់ណាស់។ ប្រសិនបើមានសញ្ញាព្រមាន សូមទៅមន្ទីរពេទ្យជាបន្ទាន់។ ការព្យាបាលជាបន្ទាន់គឺចាំបាច់ក្នុងការទប់ស្កាត់ផលវិបាក និងមរណភាពដែលអាចកើតមាន។ |
| | ទារក និងកុមារតូចងាយនឹងរងគ្រោះដោយសារជំងឺគ្រុនឈាម។ |
| **មិនមានការព្យាបាលជាក់លាក់សម្រាប់ជំងឺគ្រុនឈាមទេ។** | ករណីស្រាលៗ នឹងត្រូវបានព្យាបាលនៅលំនៅឋានដោយប្រើថ្នាំប៉ារ៉ាសេតាម៉ុលសម្រាប់ការធូរស្បើយពីការក្តៅខ្លួន ឈឺក្បាល ឈឺ និងចុកសាច់ដុំនិងឈឺសន្លាក់ដោយការសម្រាកឲ្យបានច្រើននិងការផឹកទឹកជាប្រចាំ។ |
| | អ្នកមានជំងឺគ្រុនឈាមគួរប្រើថ្នាំបណ្តេញសត្វល្អិត និងសម្រាក / ដេកនៅក្នុងមុងដើម្បីការពារសមាជិកគ្រួសារដទៃទៀតរបស់ពួកគេពីការឆ្លងមេរោគ។ |

## ការកាត់បន្ថយផលប៉ះពាល់របស់ជំងឺគ្រុនឈាមដោយការប្រើប្រាស់អាកប្បកិរិយាការពារនានា

| <u>សារសំខាន់</u> | <u>សារគាំទ្រ</u> |
|---|---|
| **ការកាត់បន្ថយជម្រកមូសគឺជាវិធីដែលមានប្រសិទ្ធភាពបំផុតក្នុងការការពារបុគ្គល និងសហគមន៍ពីជំងឺគ្រុនឈាម។** | គ្មានមូសគឺគ្មានជំងឺគ្រុនឈាម |
| | ការទប់ស្កាត់មូសមិនឲ្យបង្កាត់ពូជ និងខាំគឺជាវិធានការការពារដ៏ល្អបំផុត |
| **ការកំណត់អត្តសញ្ញាណ ការសម្អាត និងការបំផ្លាញជម្រកមូសនឹងជួយកាត់បន្ថយការឆ្លងជំងឺគ្រុនឈាមនៅក្នុងសហគមន៍។** | អ្វីគ្រប់យ៉ាងដែលអាចដក់ទឹកបានអាចជាជម្រកមូស។ វត្ថុដក់ទឹកតូចដូចជា គម្របដបមានទឹកគ្រប់គ្រាន់សម្រាប់មូសពងបាន។ |
| | ដើម្បីទប់ស្កាត់មូសមិនឲ្យមានកើតមានក្នុងគ្រួសារ និងសហគមន៍៖<br>• សម្អាតកាកសំណល់ និងសំរាមជុំវិញផ្ទះរបស់អ្នកដែលអាចដក់ទឹកបាន<br>• ប្រសិនបើមានសម្បកកង់នៅលើអចលនទ្រព្យរបស់អ្នក សូមពិនិត្យមើលថា មិនមានទឹកដក់ខាងក្នុងទេ។ បើអាចធ្វើបាន សូមទុកសម្បកកង់ឡាននៅកន្លែងដែលគ្របដិត។ |

| | |
|---|---|
| | • យ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍ ប្តូរទឹកនៅក្នុងថូ និង ផើងផ្កា និងថាសទម្រុក្ខជាតិ ឬរបស់របរផ្សេងទៀតដែលមាន ដក់ទឹក។<br>• ជានិច្ចកាល ត្រូវទុកទឹកក្នុងពាង ធុង និងក្រឡគ្របជិតដែល មានគម្របទប់ស្កាត់មូស។<br>• រាល់ធុង និងពាងស្តុកទឹកទាំងអស់គួរតែត្រូវបានសម្អាត លាង និងជូតចេញ (ជាពិសេសគែម និងទ) ម្តងក្នុងមួយសប្តាហ៍ ដើម្បីយកពងមូសចេញ។<br>• ប្រសិនបើមានបំពង់ខូច ឬលេចធ្លាយទឹកនៅកន្លែងជុំវិញអ្នក ចូររាយការណ៍ទៅអាជ្ញាធរ។ (រួមបញ្ចូលបើដែលអាចមានទាំង ព័ត៌មានលម្អិតអំពីវិធីរាយការណ៍ ដូចជាតាមរយៈលេខ ទូរសព្ទ ឬគេហទំព័រ)<br>• បង្ហូរទ-ទឹកលើដំបូល និងជានាថាទឹកហូរដោយស្រួល<br>• រាយការណ៍ពីជម្រកមូសនៅក្នុងកន្លែងដែលគេបោះបង់ចោល កន្លែងសាធារណៈ ទីធ្លាសួនកុមារ និងកន្លែងធ្វើការ។ (រួមមាន វិធី ទីកន្លែង ព័ត៌មានលម្អិតអំពីបញ្ហានេះ ដែលគេអាចរាយ ការណ៍បាន)<br>• ទឹកនៅក្នុងពាងស្តុកទឹកធំ (រហូតដល់ ៣០០ លីត្រ) គួរតែ ត្រូវបានធ្វើប្រព្រឹត្តកម្មដោយថ្នាំសម្លាប់ដង្កូវទឹកស្របតាមបទ បញ្ញាអនាម័យដើម្បីសម្លាប់ដង្កូវ និងពងមូស។ (មូស Aedes មិនកកើតនៅក្នុងពាងទឹកដែលមានទំហំធំជាង ៣០០ លីត្រ ទេ)។ |
| | វាមិនគ្រប់គ្រាន់ទេគ្រាន់តែផ្កាប់ពាង និងបង្ហូរទឹកចោលប៉ុណ្ណោះ។ មូស អាចរស់បានក្នុងពាងទទេ និងស្ងួតរហូតដល់ ៦ខែ។ នៅពេលដែលប៉ះត្រូវ នឹងទឹក នោះពងមូសញាស់ ហើយវដ្តនៃជីវិតមូសក៏ចាប់ផ្តើមម្តងទៀត។ |
| **ដោយចាត់វិធានការការពារ សាមញ្ញមួយចំនួន អ្នកអាច** | ការពារខ្លួនអ្នកដោយស្លៀកសម្លៀកបំពាក់ដែលគ្របដណ្តប់រាងកាយឲ្យ បានជិតបំផុតតាមដែលអាចធ្វើទៅបាន ប្រើថ្នាំបណ្តេញសត្វល្អិត។ |

| | |
|---|---|
| **កាត់បន្ថយលទ្ធភាពនៃមូសខាំបាន និងមានជំងឺគ្រុនឈាម។** | ព្យាយាមស្នាក់នៅក្នុងលំនៅឋាន ជាពិសេសក្នុងអំឡុងម៉ោងពេលព្រឹកព្រលឹម និងពេលរសៀលនៅពេលដែលមូសមានសកម្មភាពខ្លាំងបំផុត ប្រសិនបើអាចនៅកន្លែងដែលមានម៉ាស៊ីនត្រជាក់។ |
| **នៅពេលថែរក្សាសមាជិកគ្រួសារដែលមានជំងឺ សូមចាត់វិធានការការពារជាមុនដើម្បីការពារសមាជិកគ្រួសារផ្សេងទៀតពីមូសខាំ។** | ក្នុងអំឡុងពេលមួយសប្តាហ៍ដំបូងនៃការឆ្លង មេរោគគ្រុនឈាមគឺស្ថិតនៅក្នុងឈាមរបស់អ្នកដែលឆ្លងមេរោគៈ ប្រសិនបើមូសខាំអ្នកនោះ មេរោគអាចចម្លងទៅអ្នកផ្សេងទៀតដែលនៅជុំវិញពួកគេបាន។ |
| | ប្រសិនបើមានការសង្ស័យថា សមាជិកគ្រួសារម្នាក់អាចឆ្លងជំងឺគ្រុនឈាម ឬកំពុងមានរោគសញ្ញា ត្រូវឲ្យគាត់សសម្រាក និងដេកនៅក្នុងមុងដើម្បីការពារសមាជិកគ្រួសារផ្សេងទៀតពីជំងឺគ្រុនឈាម។ |
| | ប្រសិនបើអ្នកសង្ស័យឬឮថា សមាជិកគ្រួសារ ឬអ្នកជិតខាងឈឺដោយសារជំងឺគ្រុនឈាម សូមពង្រឹងសកម្មភាពរបស់អ្នកដើម្បីលុបបំបាត់ជម្រកមូសនៅជុំវិញគ្រួសាររបស់អ្នក ហើយជានិច្ចកាលត្រូវប្រើថ្នាំបណ្តេញសត្វល្អិតនៅពេលសម្អាត។ |
| **ការបាញ់ថ្នាំសម្លាប់មូសមិនគ្រប់គ្រាន់ក្នុងការបំផ្លាញមូសឡើយ។** | ការបាញ់ថ្នាំសម្លាប់មូសអាចកាត់បន្ថយចំនួនមូសពេញវ័យជាបណ្តោះអាសន្នបាន ប៉ុន្តែមិនអាចសម្លាប់ដង្កូវទឹកបានទេ។ |
| | នៅពេលបាញ់ថ្នាំសម្លាប់មូស យកល្អត្រូវបើកបង្អួច និងទ្វារផ្ទះរបស់អ្នកឲ្យចំហ ដើម្បីឲ្យដំណក់ទឹក និងសន្សើមចូលទៅខាងក្នុង ហើយសម្លាប់មូសពេញវ័យ។ |
| | អនុវត្តតាមការណែនាំរបស់អាជ្ញាធរក្នុងអំឡុងពេលធ្វើសកម្មភាពបាញ់ថ្នាំសម្លាប់មូស។ |

## ការយល់ដឹង និងការកៀរគរសហគមន៍

| **សារសំខាន់** | សារគាំទ្រ |
|---|---|
| **ការជូនដំណឹងអំពីជំងឺគ្រុនឈាម និងស្គាល់សញ្ញានៃការ** | ត្រូវដឹងពីស្ថានភាពជំងឺគ្រុនឈាមនៅក្នុងប្រទេស និងសហគមន៍របស់អ្នក។ |

| | |
|---|---|
| **ឆ្លងដែលអាចកើតមាន ពិតជាមានសារសំខាន់ណាស់។** | ដឹងពីរោគសញ្ញា និងសញ្ញាព្រមាននៃជំងឺគ្រុនឈាម៖ ការរកឃើញដំណាក់កាលដំបូង និងការទទួលបានការថែទាំសុខភាពត្រឹមត្រូវមានសារសំខាន់ខ្លាំងណាស់ក្នុងការការពារពីផលវិបាក និងមរណភាព។ |
| | សូមចាំថា ប្រសិនបើអ្នកមានសញ្ញាព្រមានអំពីជំងឺគ្រុនឈាមធ្ងន់ធ្ងរត្រូវទៅមន្ទីរពេទ្យជាបន្ទាន់។ ការព្យាបាលទាន់ពេលវេលាអាចជួយសង្គ្រោះជីវិតបាន។ |
| **គ្រប់គ្នាមានតួនាទីទប់ស្កាត់កុំឲ្យមូសខាំ។** | ចូលរួមក្នុងសកម្មភាពគ្រប់គ្រងសត្វល្អិតចម្លងមេរោគរបស់សហគមន៍ ហើយប្រើប្រាស់ និងលើកកម្ពស់វិធានការទប់ស្កាត់ផ្ទាល់ខ្លួន។ |
| | ចូលរួម និងលើកទឹកចិត្តដល់ការសម្អាតបរិស្ថានក្នុង និងខាងក្រៅលំនៅឋានដើម្បីលុបបំបាត់ និងកាត់បន្ថយអ្វីៗទាំងអស់ ដែលអាចដក់ទឹកនៅក្នុងគ្រួសារ តំបន់ជុំវិញផ្ទះរបស់អ្នក សាលារៀន និងកន្លែងធ្វើការ។ |

## ពេលផ្ទុះឡើងនៃជំងឺគ្រុនឈាមបានចប់

| <u>សារសំខាន់</u> | <u>សារគាំទ្រ</u> |
|---|---|
| **យើងកំពុងជួបប្រទះករណីជំងឺគ្រុនឈាមតិចតួចជាងមុន អាជ្ញាធរសុខាភិបាលនឹងបន្តតាមដានជំងឺគ្រុនឈាម។** (សារនឹងអាស្រ័យលើជំហានដូចខាងក្រោមរបស់ប្រទេស) | យើងសូមថ្លែងអំណរគុណដល់ប្រជាជនដែលបានចូលរួមយ៉ាងសកម្មក្នុងការឆ្លើយតបទៅនឹងការផ្ទុះឡើងនៃជំងឺនេះ។ ទោះបីជាយ៉ាងណាមូសរស់នៅក្នុងចំណោមពួកយើង ហើយយើងត្រូវតែបន្តធ្វើការជាមួយគ្នាដើម្បីការពារជំងឺដ៏កាចសាហាវនេះ។ |
| | ក្រសួងសុខាភិបាលនឹងនៅតែមានការប្រុងប្រយ័ត្នជានិច្ច ធ្វើប្រព័ន្ធឃ្លាំមើល និងពង្រឹងសមត្ថភាពឆ្លើយតបនៅថ្នាក់ជាតិ កម្រិតសហគមន៍ និងកម្រិតមូលដ្ឋាន។ |
| | យើងកំពុងពង្រឹងសមត្ថភាពឥតឈប់ឈរនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យសម្រាប់ការគ្រប់គ្រងជំងឺគ្រុនឈាមឲ្យបានគ្រប់គ្រាន់ដើម្បីទប់ស្កាត់ផលវិបាក និងមរណភាព។ |

| | |
|---|---|
| | យើងនឹងបន្តផ្តល់សិទ្ធិអំណាចដល់សហគមន៍ដើម្បីត្រៀមខ្លួនឲ្យបានប្រសើរសម្រាប់គ្រោះអាសន្នផ្នែកសុខភាព និងការផ្ទុះឡើងនៃជំងឺគ្រុនឈាមនាពេលអនាគត។ |
| **ទោះបីជាការផ្ទុះឡើងនៃជំងឺគ្រុនឈាមមិនអាចចៀសវាងបានក៏ដោយ តាមរយៈការអនុវត្តវិធានការទប់ស្កាត់មូសប្រកបដោយនិរន្តភាពទំហំប្រេកង់ និងផលប៉ះពាល់នៃការផ្ទុះឡើងនៃជំងឺអាចត្រូវបានកាត់បន្ថយយ៉ាងខ្លាំង។** | ជំងឺគ្រុនឈាមគឺជាជំងឺដែលអាចបណ្តាលឲ្យស្លាប់ ដែលអាចការពារបានដោយការលុបបំបាត់កន្លែងកើតមូស និងថែរក្សាបរិស្ថានឲ្យស្អាត។ នេះ ចាំបាច់ត្រូវតែមានស្ថិរភាព និងមាននិរន្តភាពក្នុងការទប់ស្កាត់ការផ្ទុះឡើងនៃជំងឺធ្ងន់ធ្ងរ និងញឹកញាប់។ |
| | ស្ថានភាពនៃការផ្ទុះឡើងនៃជំងឺគឺជាបន្ទុកសេដ្ឋកិច្ច និងសង្គមយ៉ាងធ្ងន់ធ្ងរសម្រាប់សហគមន៍ អាជ្ញាធរមូលដ្ឋាន សេវាសុខភាព និងគ្រួសារដែលថែទាំអ្នកជំងឺ។ |
| | អនុវត្តជាប្រចាំនូវវិធានការទប់ស្កាត់ជំងឺគ្រុនឈាមដើម្បីកាត់បន្ថយចំនួនមូស និងការចម្លងជំងឺ ប៉ុន្តែក៏ត្រូវស្វែងរកការព្យាបាលដំណាក់កាលដំបូងក្នុងករណីមានរោគសញ្ញាគ្រុនឈាម និងសញ្ញាព្រមានអាចជួយសង្គ្រោះអាយុជីវិត និងកាត់បន្ថយបន្ទុកលើគ្រួសារ និងសង្គម។ |

## សារសម្រាប់បុគ្គលិកសុខាភិបាល

បុគ្គលិកសុខាភិបាលគឺជាអ្នកឆ្លើយតបដំបូងក្នុងករណីមានការផ្ទុះឡើងនៃជំងឺ ហើយចាំបាច់ត្រូវត្រៀមប្រតិកម្មប្រកបដោយប្រសិទ្ធភាព និងគ្រប់គ្រងចំនួនករណីជំងឺកាន់តែខ្ពស់ជាងនេះដោយមានគោលបំណងរួមមួយ ដើម្បីជួយសង្គ្រោះជីវិត។

ទន្ទឹមនឹងនេះ សហគមន៍ជាទូទៅទុកចិត្តបុគ្គលិកថែទាំសុខភាព ហើយស្តាប់អ្វីដែលពួកគេនិយាយ។ តាមរយៈទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព បុគ្គលិកសុខាភិបាលអាចទទួលបានការយល់ដឹង និងចំណេះដឹងកម្រិតកាន់តែខ្ពស់ដែលនាំឲ្យមានការផ្លាស់ប្តូរអាកប្បកិរិយាចាំបាច់ ដើម្បីបង្ការជំងឺដែលកកើតពីមូស ជួយសង្គ្រោះជីវិត និងកាត់បន្ថយបន្ទុកដែលជំងឺទាំងនោះមានចំពោះគ្រួសារ កម្លាំងពលកម្ម និងសហគមន៍ទាំងមូល។

សាររបស់ពួកគេគួរតែត្រូវប្រើនៅក្នុងដំណាក់កាលត្រៀមរៀបចំ និងដំណាក់កាលរៀបចំផែនការដែលជាផ្នែកមួយនៃការអប់រំសុខភាពសម្រាប់វេជ្ជបណ្ឌិត និងគិលានុបដ្ឋាក គិលានុបដ្ឋាយិកា ហើយគួរតែ

ត្រូវបានកែសម្រួលដោយផ្អែកលើបរិបទ និងចំណេះដឹង ឥរិយាបថ និងការអនុវត្តរបស់សហគមន៍មូលដ្ឋាន។ សារទាំងនេះចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពដោយផ្អែកលើស្ថានភាពក្នុងអំឡុងពេលផ្ទុះឡើងនៃជំងឺ និងភាពចាំបាច់នៃការគ្រប់គ្រងគ្លីនិកដើម្បីទប់ស្កាត់មរណភាព និងកាត់បន្ថយផលប៉ះពាល់របស់ជំងឺនេះ។

## ទំនាក់ទំនងហានិភ័យគ្រប់គ្រងជំងឺគ្រុនឈាម

**I- ការឆ្លងជំងឺគ្រុនឈាមមានលទ្ធផលធំទូលាយ។ ប្រហែលជាមានមនុស្សតែ ១-២ នាក់ក្នុងចំណោម ១០ នាក់ដែលឆ្លងនឹងមានបង្ហាញរោគសញ្ញា ហើយក្នុងចំណោមរោគសញ្ញាទាំងនោះ ៥០% អាចវិវឌ្ឍទៅជាសញ្ញាព្រមាន។ ប្រសិនបើមិនបានគ្រប់គ្រងឲ្យបានឆាប់ និងត្រឹមត្រូវនៅក្នុងមន្ទីរពេទ្យទេ ពួកគេអាចស្លាប់ដោយសារជំងឺគ្រុនឈាមធ្ងន់ធ្ងរ។**

| រោគសញ្ញា | មេរោគគ្រុនឈាម |
|---|---|
| **រោគសញ្ញាជាធម្មតាលេចចេញបន្ទាប់ពីមូសខាំ៖** | ៤ - ១០ ថ្ងៃ |
| គ្រុនក្តៅខ្លាំង រយៈពេល ២ – ៧ ថ្ងៃ | (ប្រហែល ៤០ °C/ ១០៤°F) |
| *អមមកជាមួយរោគសញ្ញាយ៉ាងហោចណាស់ពីរ ដូចខាងក្រោម៖* | |
| ឈឺក្បាល | +++ |
| ឈឺខាងក្រោយភ្នែក | +++ |
| ឈឺសាច់ដុំ និងសន្លាក់ | +++ |
| កន្ទួលក្រហមៗលើដៃ និងជើង | ++ |
| ខ្សោយ ឈឺ បាត់បង់ចំណង់អាហារ | + |

កម្រិតខ្លាំងនៃរោគសញ្ញា៖

+ ទាប

++ មធ្យម

+++ ខ្ពស់

- ប្រសិនបើអ្នកជំងឺជាកុមារតូច នោះរោគសញ្ញាបន្ថែមអាចមានបង្ហាញ រួមមានការឆាប់ខឹង ភាពវង្វេងស្មារតី និងការគេងមិនលក់អមជាមួយនឹងការមិនចង់ញ៉ាំអាហារ និង /ឬក្អួត។

- ពិនិត្យរោគសញ្ញាសំខាន់ៗរបស់អ្នកជំងឺ៖ សម្ពាធឈាម អត្រាជីពចរ និងសួរថាតើអ្នកជំងឺបាននោមមិនសូវញឹកញាប់ជាងធម្មតាឬទេ។
- ទោះបីជាអ្នកជំងឺមិនក្តៅខ្លួន ប៉ុន្តែឈឺពោះ សូមសួរថាតើមានគ្រុនក្តៅក្នុងរយៈពេល ២៤ ម៉ោងចុងក្រោយទេ ជាពិសេសនៅតំបន់មានការផ្ទុះឡើងនៃជំងឺគ្រុនឈាម។ ប្រសិនបើគ្រុនក្តៅមានបង្ហាញក្នុងរយៈពេល ២៤-២៨ ម៉ោងមុន សូមគិតអំពីជំងឺគ្រុនឈាម។
- ដោយសារតែជាការធ្វើតេស្តរកជំងឺគ្រុនឈាម វាមានសារសំខាន់ខ្លាំងណាស់ក្នុងការស្នើសុំការធ្វើតេស្តរោគវិនិច្ឆ័យរហ័ស (ការធ្វើតេស្ត **NS1 antigen)** នូវករណីជំងឺគ្រុនឈាមដែលសង្ស័យណាមួយ។ វិធីសាស្ត្រធ្វើរោគវិនិច្ឆ័យនេះអាចទុកចិត្តបានសម្រាប់ការចាប់ផ្តើមគ្រុនក្តៅក្នុងរយៈពេលពីរបីថ្ងៃដំបូង។
- ការរាប់ឈាមពេញលេញ (**CBC)** គឺមានប្រយោជន៍ខ្លាំងណាស់ព្រោះអ្នកជំងឺជាញឹកញាប់មានជំងឺបាត់បង់កោសិកាឈាមស (WBC <5000 កោសិកា / μl) និង/ឬ thrombocytopenia (១៥០x១០០$^{៩}$ / លីត្រ)។
- នៅពេលដែលជំងឺកំពុងតែវិវឌ្ឍ អនុបាតកោសិកាឈាមក្រហមធៀបនឹងបរិមាណឈាម (**hematocrit)** គួរតែត្រូវត្រួតពិនិត្យឲ្យបានញឹកញាប់៖ ចំពោះអ្នកជំងឺដែលអាចនឹងមានការវិវឌ្ឍនៃការលេចធ្លាយប្លាស្មាធ្លង (ជំងឺធ្ងន់ធ្ងរ) វាអាចមានអត្រា ២០% ខ្ពស់ជាងធម្មតា ។
- ណែនាំអ្នកជំងឺថា វាមានសារសំខាន់ខ្លាំងណាស់ក្នុងការមករកការរាប់ឈាមពេញលេញ (CBC) នៅថ្ងៃទី៣។ ប្រសិនបើជំងឺបាត់បង់កោសិកាឈាមសមានបង្ហាញជាមួយនឹងការធ្វើតេស្ត **tourniquet** វិជ្ជមាន នោះលទ្ធភាពនៃការវិវឌ្ឍទៅជាជំងឺគ្រុនឈាមធ្ងន់ធ្ងររបស់អ្នកជំងឺគឺ ៨០% សម្រាប់កុមារ និង ៦០% សម្រាប់មនុស្សពេញវ័យ។
- អ្នកជំងឺភាគច្រើនដែលមានការគ្រប់គ្រងសមស្របនឹងមានអារម្មណ៍ធូរស្រាលបន្ទាប់ពីរយៈពេល ១០-១៤ ថ្ងៃ ហើយជាសះស្បើយវិញទាំងស្រុង។

## II- ណែនាំអ្នកជំងឺពីសញ្ញាព្រមាននានា៖

៣-៧ ថ្ងៃបន្ទាប់ពីរោគសញ្ញាដំបូងលេចចេញ នៅពេលដែលការលេចធ្លាយប្លាស្មាមិនត្រូវបានគេរកឃើញនោះទេ អ្នកជំងឺអាចចូលទៅក្នុងប្រភេទជំងឺ hypovolemic shock។

ណែនាំអ្នកជំងឺឲ្យស្វែងរកការព្យាបាលជាបន្ទាន់នៅមន្ទីរពេទ្យ ប្រសិនបើគ្រុនក្ដៅបានធ្លាក់ចុះ (ហាក់ដូចជាអ្នកជំងឺមានអារម្មណ៍ធូរស្រាល) ប៉ុន្តែមានសញ្ញាព្រមានបង្ហាញ៖ ឈឺក្រពះធ្ងន់ធ្ងរ ក្អួតជាប់រហូត ដកដង្ហើមញាប់ៗ អញ្ចាញធ្មេញហូរឈាម អស់កម្លាំងហើយប្រឫកច្របល់ព្រមជាមួយនឹងការមិនស្រួល និងឈាមពេលក្អួតរួមជាមួយទាំងទឹកនោមថយចុះ។ ការព្យាបាលបែបវេជ្ជសាស្ត្រដំណាក់កាលដំបូងអាចជួយសង្គ្រោះអាយុជីវិតបាន។

- ពន្យល់ថា នៅពេលសញ្ញាព្រមានទាំងនេះបង្ហាញ ការទៅមន្ទីរពេទ្យជាបន្ទាន់ពិតជាមានសារសំខាន់បំផុត។ ការព្យាបាលនៅមន្ទីរពេទ្យជាបន្ទាន់គឺចាំបាច់ណាស់ដើម្បីការពារផលវិបាក និងមរណភាពដែលអាចកើតមាន។
- ប្រសិនបើអ្នកជំងឺជាកុមារអាយុក្រោម ១៨ ខែហើយមានគ្រុនក្ដៅខ្លាំង ត្រូវបញ្ជូនទៅមន្ទីរពេទ្យដោយផ្ទាល់។
- ចំពោះក្មេងធំៗ សូមផ្ដល់ដំបូន្មានដល់អ្នកថែទាំឲ្យប្រយ័ត្នប្រយែងបំផុតចំពោះការផ្លាស់ប្ដូរស្ថានភាពណាមួយ (ការធ្លាក់ចុះគ្រុនក្ដៅភ្លាមៗ ទឹកនោមចេញតិចជាងមុន ស្លេកស្លាំង និងស្បែកត្រជាក់ ឆាប់ខឹងខ្លាំងគឺគ្រាន់តែជាសញ្ញាព្រមានខ្លះៗ) ត្រូវនាំកុមារទៅមន្ទីរពេទ្យជាបន្ទាន់។

**III - ការព្យាបាលជំងឺគ្រុនឈាម៖**

- មិនមានការព្យាបាលជាក់លាក់ណាមួយសម្រាប់ជំងឺគ្រុនឈាមទេ។
- បញ្ជាក់ពីសារសំខាន់នៃការមិនប្រើប្រាស់ថ្នាំដែលមិនមានវេជ្ជបញ្ជាពីវេជ្ជបណ្ឌិត។
- ចេញវេជ្ជបញ្ជាថ្នាំអាសេតាមីណូហ្វេន ឬប៉ារ៉ាសេតាម៉ុលសម្រាប់គ្រុនក្ដៅ ឈឺក្បាល ឈឺ និងចុកចាប់ផ្សេងៗ។
- ណែនាំឲ្យសម្រាកឲ្យបានច្រើន និងផ្ដល់ជាតិទឹកឲ្យបានទៀងទាត់ជាមួយ ORS ទឹក ទឹកដូង ស៊ុបជាដើម ដោយស្លាបព្រា ឬដោយការបឺតតិចៗឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។
- ពន្យល់ថា ជំងឺគ្រុនឈាមមិនឆ្លងដោយផ្ទាល់ពីមនុស្សម្នាក់ទៅមនុស្សទេ។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីការពារក្រុមគ្រួសារផ្សេងទៀត សូមបញ្ជាក់ថាមេរោគនេះរស់នៅក្នុងឈាមរបស់អ្នកជំងឺចាប់ពីថ្ងៃមុនពេលគ្រុនក្ដៅរហូតដល់ ១២ ថ្ងៃបន្ទាប់។ ដូច្នេះ ប្រសិនបើអ្នកជំងឺត្រូវមូសខាំម្ដងទៀត នោះមេរោគអាចចម្លងទៅសមាជិកគ្រួសារផ្សេងទៀត។ ដូច្នេះ វាមានសារសំខាន់ណាស់ក្នុងការចៀសវាងមូសខាំដោយប្រើថ្នាំបណ្ដេញសត្វល្អិត និងធូបមូស ឧបករណ៍បណ្ដេញសត្វល្អិតនៅខាងក្នុង

លំនៅឋាន។ ការប្រើមុងលើគ្រែដោយអ្នកជំងឺគ្រុនឈាមក៏ត្រូវបានណែនាំផងដែរ នៅពេលសម្រាក និងគេងនោះ។ ប្រសិនបើអាចធ្វើបាន វាជាការល្អបំផុតក្នុងការស្នាក់នៅខាងក្នុងលំនៅឋានពេញមួយថ្ងៃ ជាពិសេសនៅក្នុងបន្ទប់ដែលមានម៉ាស៊ីនត្រជាក់។

**IV- នៅតាមតំបន់ដែលងាយកើតជំងឺគ្រុនឈាម សូមរំឭកដល់អ្នកជំងឺទាំងអស់របស់អ្នកឲ្យធ្វើដូចខាងក្រោម៖**

- លុបបំបាត់ជម្រកមូសទាំងអស់នៅជុំវិញ និងខាងក្នុងលំនៅឋាន និងកន្លែងធ្វើការ។ ពេលកំពុងធ្វើដូចនេះ ជានិច្ចកាលត្រូវប្រើថ្នាំបណ្ដេញសត្វល្អិតផងដែរ។
- ពន្យល់ថា មូសផ្ទុកជំងឺគ្រុនឈាមអាចកកើតបានសូម្បីតែក្នុងរបស់របរដក់ទឹកតូចបំផុតមួយ ឬការសំណល់សំរាមនានាដែលអាចដក់ទឹកបាន (ដូចជាគម្របដបជាដើម)។
- ប្រសិនបើគ្រួសារត្រូវការត្រងទឹកទុក សូមណែនាំឲ្យគ្របពាងទឹកទាំងអស់ឲ្យជិត (ជាមួយគម្របទប់ស្កាត់មូស ប្រសិនបើអាច) ប្ដូរទឹករៀងរាល់សប្ដាហ៍ ហើយលាងសម្អាត និងជូតពាង ព្រោះថាពងមូសអាចលាក់នៅក្នុងស្នាមប្រេះ និងផ្នែកខូចខាតណាមួយនៃពាងទឹកបាន។ ពងមូសអាចរស់បានរហូតដល់ទៅ ៦ខែក្នុងធុងទទេហើយស្ងួត ប៉ុន្តែនៅពេលប៉ះជាមួយទឹក ពងទាំងនោះចាប់ ផ្តើមវដ្តនៃជីវិតម្តងទៀត។
- ស្លៀកសម្លៀកបំពាក់ពណ៌ភ្លឺៗ ដែលគ្របដណ្ដប់លើរាងកាយភាគច្រើន និងប្រើថ្នាំបណ្ដេញមូស។
- អនុវត្តតាមដំបូន្មានដែលផ្ដល់ជូនដោយអាជ្ញាធរសុខាភិបាល។

## សារស្ដីពីជំងឺគ្រុនឈាមសម្រាប់អ្នកថែទាំកុមារ និងកុមារតូចៗ

- ជំងឺគ្រុនឈាមគឺជាជំងឺមួយដែលចម្លងដោយមូសដែលពេលខ្លះអាចវិវឌ្ឍទៅជាផលវិបាកធ្ងន់ធ្ងរ និងរហូតដល់ទទួលមរណភាពផងដែរ។
- ជំងឺគ្រុនឈាមចម្លងដោយមូសដែលរស់នៅជិតគ្រួសារ ហើយអាចកកើតនៅក្នុងវត្ថុណាមួយដែលដក់ទឹកសូម្បីតែរបស់របរដក់តូចបំផុត ដូចជាគម្របដប។ ទោះជាយ៉ាងណាក៏ដោយ ធុងកាន់តែធំមូសអាចពងកាន់តែច្រើន។
- មូសដែលចម្លងជំងឺគ្រុនឈាមអាចដាក់ពងដែលមានផ្ទុកមេរោគរួចហើយ ហើយនឹងក្លាយជាសត្វល្អិតចម្លងមេរោគពេញវ័យសម្រាប់ជំងឺនេះ។ ក្នុងករណីនោះ មិនចាំបាច់ខាំមនុស្សមុននឹងចម្លងជំងឺទេ។

នៅពេលមូសខាំមនុស្សម្នាក់ដែលឆ្លងមេរោគគ្រុនឈាម មូសអាចក្លាយជាអ្នកចម្លងមេរោគនោះ បាន។ ប្រសិនបើមូសនេះខាំមនុស្សម្នាក់ទៀត នោះមនុស្សម្នាក់នោះក៏អាចឆ្លងជំងឺគ្រុនឈាម និងមានបង្ហាញ ឬគ្មានបង្ហាញរោគសញ្ញា ប៉ុន្តែនៅតែជាប្រភពនៃការចម្លងមេរោគដដែល។

ប្រសិនបើអ្នករស់នៅក្នុងទីតាំងដែលមានជំងឺគ្រុនឈាម ត្រូវដឹងថាៈ

- ក្នុងករណីភាគច្រើន ជំងឺគ្រុនឈាមនឹងមិនបង្ហាញរោគសញ្ញា ឬគ្រាន់តែបង្ហាញរោគសញ្ញាស្រាលខ្លាំងប៉ុណ្ណោះចំពោះកុមារដែលបានឆ្លងមេរោគ។
- រោគសញ្ញាជាធម្មតាចាប់ផ្តើមពី ៤ - ១០ ថ្ងៃបន្ទាប់ពីមូសខាំ ប៉ុន្តែជំងឺគ្រុនឈាមអាចពិបាកសម្គាល់ព្រោះរោគសញ្ញាស្រដៀងនឹងការឆ្លងជំងឺទូទៅផ្សេងទៀត។
- សូមគិតពីជំងឺគ្រុនឈាម ប្រសិនបើកុមារៈ
    - មានគ្រុនក្តៅខ្លួន អាចមានសីតុណ្ហភាពខ្ពស់ដល់១០៥°F (៤០°C)
    - ខឹង ឆេវឆាវ រវើរវាយ ឬងុយដេកខ្លាំង
    - មិនព្រមញ៉ាំអាហារ និងក្អួត
    - ប្រាប់ថា ដងខ្លួន និងក្បាលរបស់ពួកគេឈឺ (ប្រសិនបើកុមារមានអាយុច្រើនអាចមានទំនាក់ទំនងផ្ទាល់មាត់បាន )
    - មានបង្ហាញកន្ទួលក្រហមៗលើដងខ្លួនរបស់ពួកគេ និង
    - ជួនកាល មានហូរឈាមតិចៗពីច្រមុះ ឬអញ្ចាញធ្មេញ

- ប្រសិនបើកូនរបស់អ្នកជាពិសេស ប្រសិនបើកូនរបស់អ្នកមានអាយុក្រោម ២ឆ្នាំមានអាការក្តៅខ្លួនខ្លាំង ចាំបាច់ត្រូវនាំកូនរបស់អ្នកទៅមន្ទីរពេទ្យជាបន្ទាន់។
- ដើម្បីធ្វើឲ្យប្រាកដថា កុមារមានជំងឺគ្រុនឈាម វេជ្ជបណ្ឌិតនឹងស្នើសុំឲ្យធ្វើតេស្តឈាមបន្ថែមទៀត។
- មិនមានការព្យាបាលជាក់លាក់សម្រាប់ជំងឺគ្រុនឈាមឡើយ។
- វេជ្ជបណ្ឌិតនឹងចេញវេជ្ជបញ្ជាឲ្យប្រើថ្នាំដើម្បីគ្រប់គ្រងគ្រុនក្តៅ និងការមិនស្រួលខ្លួន។ កុំព្យាបាលកុមារដោយប្រើថ្នាំណាមួយរហូតដល់ពិគ្រោះជាមួយវេជ្ជបណ្ឌិតជាមុនសិន។
- បន្តបំបៅកូនដោយទឹកដោះប្រសិនបើអ្នកកំពុងបំបៅដោះកូន។
- ត្រូវធ្វើឲ្យប្រាកដថា កូនរបស់អ្នកផឹកទឹកឲ្យបានច្រើនដើម្បីបង្ការការខ្វះជាតិទឹក។
- កុមារគួរមានពេលសម្រាកច្រើន ប៉ុន្តែត្រូវស្ថិតនៅក្នុងមុងទប់ស្កាត់មូសដោយស្លៀកសម្លៀកបំពាក់ស្រាលៗ ដែលគ្របដណ្តប់ផ្នែកភាគច្រើននៃខ្លួនដើម្បីការពារកុំអោយមូសខាំ និងការចម្លងមេរោគជំងឺគ្រុនឈាមដល់សមាជិកគ្រួសារដទៃទៀត។ ប្រើថ្នាំបណ្តេញមូសដែលណែនាំសម្រាប់កុមារ។
- ខណៈពេលកំពុងមើលថែកុមារដែលឈឺ សូមអនុវត្តតាមវិធានការការពារខ្លួន និងប្រើថ្នាំបណ្តេញមូស។

ស្គាល់សញ្ញាព្រមាននៃផលវិបាករបស់ជំងឺគ្រុនឈាមៈ ប្រសិនបើកូនរបស់អ្នកមានបង្ហាញការធ្លាក់ចុះគ្រុនក្តៅភ្លាមៗ (តិចជាង ៣៦ °C ឬ ៩៦,៨ °F) វាធាប់ខឹង មានអារម្មណ៍ឈឺ ក្អួត មានស្បែកស្លេក ត្រជាក់ ឈឺពោះ និងជួនកាលពិបាកដកដង្ហើម។ ការព្យាបាលបែបវេជ្ជសាស្ត្រគឺជារឿងចាំបាច់បន្ទាន់។ កុំរង់ចាំសូមទៅមន្ទីរពេទ្យដោយផ្ទាល់។ ២៤ម៉ោងដំបូងគឺមានសារសំខាន់ខ្លាំងណាស់។ ការព្យាបាលវេជ្ជសាស្ត្រដំណាក់កាលដំបូងអាចជួយសង្គ្រោះជីវិតកុមារបាន។

## ឧបសម្ព័ន្ធទី២៖ ផែនការគោរអប់រំសុខភាព និងទំនាក់ទំនងហានិភ័យ សម្រាប់ជំងឺគ្រុនឈាម ឆ្នាំ ២០១៩ - ២០២០

1. **ពង្រឹងសកម្មភាពទំនាក់ទំនងហានិភ័យសម្រាប់ការវិភាគរោគវិនិច្ឆ័យដំណាក់កាលដំបូង និងការគ្រប់គ្រងគ្លីនិក (ទំនាក់ទំនងការគ្រប់គ្រងជំងឺគ្រុនឈាម)**

*ឆ្លើយតបនឹងគោលបំណង ១.៤ ពីផែនការសកម្មភាពជាតិ៖ អភិវឌ្ឍសមត្ថភាពវេជ្ជបណ្ឌិត និងបុគ្គលិកគាំទ្រ (សាកលវិទ្យាល័យសាធារណៈ / ឯកជន)*

| សកម្មភាព | សកម្មភាពបន្ទាប់បន្សំ | សូចនាករ | ការទទួលខុសត្រូវ | ពេលវេលា |
|---|---|---|---|---|
| ការកសាងសមត្ថភាពទំនាក់ទំនងការគ្រប់គ្រងជំងឺគ្រុនឈាម | ការបណ្តុះបណ្តាលថ្នាក់ខេត្តសម្រាប់បុគ្គលិកគ្លីនិកសុខភាពបឋម / គ្រូពេទ្យទូទៅ និងគិលានុបដ្ឋាក គិលានុបដ្ឋាយិកា | ចំនួនការបណ្តុះបណ្តាលដែលបានធ្វើ ចំនួនវេជ្ជបណ្ឌិតដែលបានបណ្តុះ បណ្តាល | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ / កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាមអនុ គណៈកម្មការគ្លីនិក អង្គការសុខភាពពិភពលោក | តុលា – វិច្ឆិកា ២០១៩ |

| | | | | |
|---|---|---|---|---|
| បង្កើតសម្ភារព័ត៌មាន ការអប់រំ និងទំនាក់ទំនង ជាក់លាក់សម្រាប់គ្រូពេទ្យទូទៅ | រចនា បង្កើត និងចែកចាយសម្ភារទំនាក់ទំនងជាក់លាក់ | ចំនួនគ្លីនិកសុខភាពដែលមានសម្ភារ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ / កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង អនុគណៈកម្មការគ្លីនិក អង្គការសុខភាពពិភពលោក | ចុងឆ្នាំ ២០១៩ |
| | បង្កើតនូវតំណភ្ជាប់បន្ថែមលើគេហទំព័ររបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងជាមួយនឹងសម្ភារព័ត៌មាន ការអប់រំ និងទំនាក់ទំនងសម្រាប់គ្រូពេទ្យ | ជារៀងរាល់ថ្ងៃ ចូលទៅ និងទាញយកសម្ភារពីមីក្រូគេហទំព័រ | នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ / កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម | ត្រីមាសទី១ ឆ្នាំ ២០២០ |

**2.** បង្កើតយន្តការសម្របសម្រួលទំនាក់ទំនងជាមួយនឹងដៃគូ និងភាគីពាក់ព័ន្ធផ្សេងៗ

*ឆ្លើយតបនឹងគោលបំណង ៤.២ ពីផែនការសកម្មភាពជាតិ៖ បង្កើតយន្តការសម្របសម្រួលអន្តរវិស័យមួយដើម្បីដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការប្រយុទ្ធនឹងជំងឺគ្រុនឈាម*

| សកម្មភាព | សកម្មភាពបន្ទាប់បន្សំ | សូចនាករ | ការទទួលខុសត្រូវ | ពេលវេលា |
|---|---|---|---|---|
| បង្កើតក្រុមការងារទំនាក់ទំនងអន្តរវិស័យ | ជនបង្គោលទំនាក់ទំនងត្រូវបានកំណត់អត្តសញ្ញាណ | បញ្ជីសមាជិកគណៈកម្មការទំនាក់ទំនង | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ /កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម | ខែតុលា ឆ្នាំ ២០១៩ |
| | កិច្ចប្រជុំជាមួយនឹងក្រុមការងារដើម្បីពិនិត្យ និងឯកភាពលើយុទ្ធសាស្ត្រទំនាក់ទំនង | ជំនួយដល់កិច្ចប្រជុំប្រចាំឆ្នាំចំនួន៣ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ /កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម | អចិន្ត្រៃយ៍ |
| បង្កើតសម្ភារតស៊ូមតិដើម្បីពង្រឹង និងចរចា ការប្តេជ្ញាចិត្ត និងគាំទ្រហួសពីវិស័យសុខាភិបាល | ការបង្កើតសម្ភារការតស៊ូមតិជាក់លាក់សម្រាប់ភាគីពាក់ព័ន្ធម្ចាស់ជំនួយ និងដៃគូ | សម្ភារការតស៊ូមតិជាក់លាក់ត្រូវបានបង្កើត | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ /កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម | ឆមាសទីមួយ ឆ្នាំ២០២០ |

| | | | | |
|---|---|---|---|---|
| | | | នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង អង្គការសុខភាពពិភពលោក | |

**3. បង្កើតយុទ្ធសាស្ត្រទំនាក់ទំនងហានិភ័យ និងការចូលរួមរបស់សហគមន៍ទំលំទូលាយសម្រាប់ការរកឃើញជំងឺគ្រុនឈាមដំណាក់កាលដំបូង ការស្វែងរកការព្យាបាលវេជ្ជសាស្ត្រទាន់ពេលវេលា និងអនាម័យបរិស្ថានចីរភាពសម្របតាមក្រុមគោលដៅដែលបានកំណត់**

*ឆ្លើយតបនឹងគោលបំណង ៤.៦ ពីផែនការសកម្មភាពជាតិ៖ បង្កើតកញ្ចប់ព័ត៌មាន ការអប់រំ និងទំនាក់ទំនង/ទំនាក់ទំនងផ្លាស់ប្តូរអាកប្បកិរិយាពីការស្វែងរកការថែទាំសុខភាព ការទប់ស្កាត់ និងការគ្រប់គ្រងដំណាក់កាលដំបូង*

| សកម្មភាព | សកម្មភាពបន្ទាប់បន្សំ | សូចនាករ | ការទទួលខុសត្រូវ | ពេលវេលា |
|---|---|---|---|---|
| ធ្វើការស្រាវជ្រាវអំពីការយល់ឃើញពីហានិភ័យ | ធ្វើការសិក្សា KAP ឬក្រុមផ្តោតលើជំងឺគ្រុនឈាមនៅក្នុងសហគមន៍ដែលទទួលផលប៉ះពាល់បំផុត | ចំនួនអ្នកចូលរួមក្នុងការស្ទង់មតិ ចំនួនក្រុមផ្តោតលើជំងឺគ្រុនឈាមដែលបានធ្វើ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ / កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង ដៃគូអភិវឌ្ឍន៍ បុគ្គលិកមន្ទីរពេទ្យសាធារណៈថ្នាក់ | ធមាសទីមួយ ឆ្នាំ២០២០ |

| | | | | |
|---|---|---|---|---|
| | | | ស្រុក និងអនុស្រុក | |
| ពង្រឹងសកម្មភាពចូលរួមរបស់សហគមន៍សម្រាប់ទិវាជំងឺគ្រុនឈាម | រៀបចំសកម្មភាពសហគមន៍នៅក្នុងកាសាលារៀន មណ្ឌលសុខភាព កន្លែងធ្វើការ តំបន់ជិតខាង | ចំនួនសាលារៀន មណ្ឌលសុខភាព វត្តអារាម អាជីវកម្មនានា ជាដើម ដែលបានចូលរួមក្នុងសកម្មភាពទិវាជំងឺគ្រុនឈាម | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ / កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម ដៃគូអភិវឌ្ឍន៍ បុគ្គលិកមន្ទីរពេទ្យសាធារណៈថ្នាក់ស្រុក និងអនុស្រុក | ទិវាជំងឺគ្រុនឈាម ឆ្នាំ ២០២០ |
| | ធ្វើឲ្យមានការចូលរួមពីអាជ្ញាធរក្នុងស្រុក ប្រធានសាសនា និងអ្នកមានឥទ្ធិពលក្នុងសហគមន៍នានានៅក្នុងការរៀបចំ និងការអនុវត្តសកម្មភាពទិវាជំងឺគ្រុនឈាម | ចំនួនកិច្ចប្រជុំដែលបានធ្វើបញ្ជីអ្នកចូលរួម | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ / កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម បុគ្គលិកមន្ទីរពេទ្យសាធារណៈ ថ្នាក់ស្រុក និងអនុស្រុក | កុម្ភៈ ដល់ មិថុនា ឆ្នាំ២០២០ |

| | | | | |
|---|---|---|---|---|
| បង្កើតសម្ភារ IEC ជាក់លាក់ស្របតាមទស្សនិកជនគោលដៅ | ការរចនា ការធ្វើតេស្ត ផលិតកម្ម ការកំណត់នូវបណ្ដាញសមស្របនិងការចែកចាយសម្ភារទំនាក់ទំនងជាក់លាក់ | ចំនួនសម្ភារដែលបានបង្កើតដោយទស្សនិកជនគោលដៅ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ / កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម / ការអប់រំសុខភាព<br>នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង<br>អង្គការសុខភាពពិភពលោក<br>ដៃគូអភិវឌ្ឍន៍ | កំពុងដំណើរការ |
| | បង្កើតមីក្រូគេហទំព័រនៅលើគេហទំព័រមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ និង នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងដោយមានសម្ភារព័ត៌មាន ការអប់រំ និងទំនាក់ទំនង | ការចូលប្រើ និងទាញយកសម្ភារពីមីក្រូគេហទំព័រប្រចាំខែ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ / កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម<br>នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង | កំពុងដំណើរការ |

| | | | | |
|---|---|---|---|---|
| | សម្រាប់ក្រុមគោលដៅនានា | | | |
| ធ្វើសិក្ខាសាលាអំពីប្រព័ន្ធផ្សព្វផ្សាយរាល់ពីរឆ្នាំម្តង | រៀបចំវគ្គប្រព័ន្ធផ្សព្វផ្សាយអំពីជំងឺគ្រុនឈាម | បញ្ជីអ្នកចូលរួម | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ / កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម | សិក្ខាសាលាទីមួយមុនចុងឆ្នាំ ២០១៩ |
| | ធ្វើការប្រកាសព័ត៌មានអំពីស្ថានភាពជំងឺគ្រុនឈាមច្បាស់លាស់ | ការប្រកាសព័ត៌មានដោយមានព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាព | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ / កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង | នៅពេលចាំបាច់ |
| ធ្វើការអប់រំសុខភាព និងទំនាក់ទំនងហានិភ័យតាមសហគមន៍ | ចែករំលែកសារសំខាន់អំពីជំងឺគ្រុនឈាម និងទំនាក់ទំនងហានិភ័យនានានៅកម្រិតសហគមន៍ | ផ្សព្វផ្សាយផ្ទាល់នូវសារនានានៅក្នុងសហគមន៍ (ភូមិ វត្តអារាម កន្លែងធ្វើការ រោងចក្រ និងសាលារៀន | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ / កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម | មុនពេល និងអំឡុងពេលរដូវកាលមានជំងឺគ្រុនឈាមច្រើន (ឧសភា-កញ្ញា) |

| | | | | |
|---|---|---|---|---|
| | | ដែលមានអត្រាឆ្លងជំងឺខ្ពស់) | | |

**4. បង្កើតយុទ្ធសាស្ត្រផ្តល់សិទ្ធិអំណាចដល់សហគមន៍ និងទំនាក់ទំនងហានិភ័យជំងឺគ្រុនឈាមសម្រាប់ការត្រៀម និងការឆ្លើយតបនឹងការផ្ទុះឡើងនៃជំងឺគ្រុនឈាម**

| សកម្មភាព | សកម្មភាពបន្ទាប់បន្សំ | សូចនាករ | ការទទួលខុសត្រូវ | ពេលវេលា |
|---|---|---|---|---|
| បង្កើតយុទ្ធសាស្ត្រអប់រំសុខភាព និងទំនាក់ទំនងហានិភ័យជំងឺគ្រុនឈាម | ពន្យល់លម្អិតអំពីឯកសារ | យុទ្ធសាស្ត្របានបង្កើតឡើង និងអនុម័ត | អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ /កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម | ខែកញ្ញា ឆ្នាំ ២០១៩ |
| | ចែករំលែកយុទ្ធសាស្ត្រជាមួយនឹងភាគីពាក់ព័ន្ធ | បញ្ជីអ្នកចូលរួមសម្រាប់កិច្ចប្រជុំភាគីពាក់ព័ន្ធ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ /កម្មវិធី | ខែតុលា ឆ្នាំ ២០១៩ |

| | | | | |
|---|---|---|---|---|
| | | | ជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម | |
| ការកសាងសមត្ថភាពទំនាក់ទំនងហានិភ័យ | ការបណ្ដុះបណ្ដាលពីទំនាក់ទំនងហានិភ័យសម្រាប់អ្នកគ្រប់គ្រងជំងឺគ្រុនឈាមថ្នាក់ជាតិ និងថ្នាក់ខេត្ត | % នៃអ្នកគ្រប់គ្រងជំងឺគ្រុនឈាមដែលបានបណ្ដុះបណ្ដាលមកពីខេត្តទាំងអស់ ២៥ | អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ / កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម | តុលា – វិច្ឆិកា ២០១៩ |
| ការសម្របសម្រួលនៃយន្តការទំនាក់ទំនងអំឡុងពេលផ្ទុះឡើងនៃជំងឺ | ចែករំលែកសារសំខាន់អំឡុងពេលផ្ទុះឡើងនៃជំងឺជាមួយនឹងក្រុមទំនាក់ទំនងអន្តរវិស័យ | យន្តការសម្រាប់ការចែករំលែកសារត្រូវបានបង្កើត | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ / កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង | កំពុងដំណើរការ |
| | ត្រួតពិនិត្យពីការផ្សព្វផ្សាយនូវសារនៅ | សូចនាករប្រព័ន្ធ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹង | កំពុងដំណើរការ |

| | | | | |
|---|---|---|---|---|
| | លើវេទិកាទំនាក់ទំនងវិស័យផ្សេងៗ | ផ្សព្វផ្សាយសង្គម ការចូលប្រើប្រាស់គេហទំព័រ | ជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ /កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម | |

## ឧបសម្ព័ន្ធទី៣៖ បញ្ជីត្រួតពិនិត្យទំនាក់ទំនងជំងឺគ្រុនឈាម

ក្នុងអំឡុងចន្លោះពេលឆ្លងជំងឺ / មុនពេលមានការផ្ទុះឡើងនៃជំងឺ៖

- ☐ ការស្រាវជ្រាវសំខាន់ត្រូវបានធ្វើឡើង - (ដូចជា ការស្ទង់មតិអំពីចំណេះដឹង អាកប្បកិរិយា និងការអនុវត្ត ឬការពិភាក្សាក្រុមផ្តោតលើជំងឺគ្រុនឈាម) ដើម្បីយល់ដឹងពីជំនឿ និងឥរិយាបថរបស់សហគមន៍ដែលមានស្រាប់ទាក់ទងនឹងជំងឺគ្រុនឈាម។

- ☐ ផែនការ និងយុទ្ធសាស្ត្រការអប់រំសុខភាព និងទំនាក់ទំនងហានិភ័យជំងឺគ្រុនឈាមត្រូវបានចែករំលែក និងគាំទ្រដោយភាគីពាក់ព័ន្ធទាំងអស់

- ☐ អ្នកគ្រប់គ្រងរបស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាមនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត និងភាគីពាក់ព័ន្ធសំខាន់ៗដែលបានបណ្តុះបណ្តាលនៅក្នុងការអប់រំសុខភាព និងទំនាក់ទំនងហានិភ័យជំងឺគ្រុនឈាម

- ☐ យន្តការសម្របសម្រួលមាននៅកន្លែង៖ តំបន់ដឹកនាំរបស់ក្រសួងសុខាភិបាលត្រូវបានបង្កើតឡើង ភាគីរដ្ឋាភិបាល និងភាគីអភិវឌ្ឍន៍ពាក់ព័ន្ធនានាត្រូវបានកំណត់អត្តសញ្ញាណ ហើយមាននីតិវិធីប្រតិបត្តិការស្តង់ដារក្នុងការសម្របសម្រួលសកម្មភាពទំនាក់ទំនងហានិភ័យនានាក្នុងករណីមានការផ្ទុះឡើងនៃជំងឺ។

- ☐ អ្នកនាំពាក្យត្រូវបានកំណត់អត្តសញ្ញាណ និងបានបណ្តុះបណ្តាល

- ☐ បណ្តាញការចូលរួមរបស់សហគមន៍ត្រូវបានបង្កើត – អ្នកដឹកនាំ និងអ្នកមានឥទ្ធិពលកម្រិតសហគមន៍ត្រូវបានអប់រំអំពីយុទ្ធសាស្ត្រចូលរួមរបស់សហគមន៍ក្នុងការផ្សព្វផ្សាយសារ អំពីការគ្រប់គ្រង និងការទប់ស្កាត់ជំងឺគ្រុនឈាម ឬជួយកាត់បន្ថយការផ្ទុះឡើងនៃជំងឺ ប្រសិនបើចាំបាច់

- ☐ មន្ត្រីបច្ចេកទេសការអប់រំសុខភាព/ទំនាក់ទំនងហានិភ័យ (ទំនាក់ទំនង) ពីកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាមមានវត្តមាននៅកិច្ចប្រជុំរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ/កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម និងគណៈកម្មការជាតិ ប្រយុទ្ធនឹងជំងឺគ្រុនឈាម

- ☐ សារ និងសម្ភារសំខាន់ៗត្រូវបានបង្កើតដែលអាចត្រូវបានប្រើប្រាស់នៅដំណាក់កាលឆ្លងទៅវិញទៅមក និងអំឡុងពេលផ្ទុះឡើងនៃជំងឺ

☐ នីតិវិធីបកស្រាយបំភ្លឺសម្រាប់ការចែករំលែកព័ត៌មានដែលបានព្រមព្រៀង

## អំឡុងពេលផ្ទុះឡើងនៃជំងឺ

☐ បុគ្គលដែលទទួលខុសត្រូវក្នុងទំនាក់ទំនងហានិភ័យកំពុងជួយវគ្គគណៈកម្មការគ្រោះអាសន្ន

☐ សារសំខាន់ត្រូវបានធ្វើបច្ចុប្បន្នភាព (ប្រសិនបើចាំបាច់) និងចំណុចត្រូវនិយាយសម្រាប់អ្នកនាំពាក្យត្រូវបានពន្យល់លម្អិត

☐ អ្នកនាំពាក្យត្រូវបានពន្យល់ និងត្រូវបានរៀបចំ

☐ ដំណើរការបកស្រាយបំភ្លឺមាននៅកន្លែង – ព័ត៌មានត្រូវបានបកស្រាយបំភ្លឺប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា

☐ សេចក្តីប្រកាសព័ត៌មានដែលបានបញ្ចេញ/សន្និសីទសារព័ត៌មានដែលបានធ្វើឡើងជាមួយអាជ្ញាធរសុខាភិបាលដើម្បីប្រកាសដំណាក់កាលដំបូងពីស្ថានភាព និងការពារពាក្យចចាមអារ៉ាម និងព័ត៌មានមិនត្រឹមត្រូវ - ការចែករំលែកព័ត៌មានអំពីអ្វីដែលគេដឹងនិងអ្វីដែលមិនដឹងក៏ដូចជាអ្វីដែលបានធ្វើឡើងនាពេលបច្ចុប្បន្នដើម្បីកាត់បន្ថយជំងឺនេះ។

☐ ចែករំលែកព័ត៌មានដល់ដៃគូតាមរយៈបណ្តាញ និងយន្តការដែលបានបង្កើតពីមុន និងសម្របសម្រួលការផ្សព្វផ្សាយព័ត៌មាន

☐ មានយន្តការនៅកន្លែងដើម្បីប្រមូលព័ត៌មានពីសហគមន៍ រួមទាំងការត្រួតពិនិត្យប្រព័ន្ធផ្សព្វផ្សាយ (រួមបញ្ចូលទាំងប្រព័ន្ធផ្សព្វផ្សាយសង្គម) ដើម្បីធ្វើការវិភាគការយល់ឃើញពីហានិភ័យយ៉ាងរហ័ស - យុទ្ធវិធីទំនាក់ទំនង និងសារដែលត្រូវបានកែសម្រួលយោងទៅតាមការវាយតម្លៃ

☐ គេហទំព័រស្ថាប័នធ្វើបច្ចុប្បន្នភាពប្រចាំថ្ងៃ/ប្រចាំសប្តាហ៍អំពីស្ថានភាព និងសារសំខាន់

☐ ទំនាក់ទំនងជាមុនជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ (ការប្រកាសមុន)

☐ ទំនាក់ទំនងជាប្រចាំតាមរយៈបណ្តាញជាច្រើនជាមួយនឹងប្រជាជនដែលទទួលផលប៉ះពាល់ សាធារណជនទូទៅ ភាគីពាក់ព័ន្ធ និងដៃគូ

[i]https://www.cdc.gov/dengue/training/cme/ccm/page51440.html

[ii] Hahn H, Chastel C. Dengue in Cambodia in 1963. Nineteen laboratory-proved cases. ***Am J Trop Med Hyg*** 1970; 19: 106-9 pmid: 5416281.